**អនុស្សរណៈ**

**ផ្ញើជូន៖** **ចៅក្រម យូ ឧត្តរា និងចៅក្រម Claudia FENZ សហចៅក្រមរបាយការណ៍ស្តីពីមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ**

**មកពី៖** **មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម មជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងមជ្ឈមណ្ឌលឯកសារកោះថ្ម**

**កាលបរិច្ឆេទ៖** **ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១**

**កម្មវត្ថុ៖** **ចម្លើយតបទៅនឹងសេចក្តីអំពាវនាវសុំឲ្យចូលរួមជាគំនិតស្តីពីមុខងារនៅសេសសល់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹងជនរងគ្រោះ**

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង “AVPC” (ដែលជាមជ្ឈមណ្ឌលសិក្សាធិការថ្នាក់ខេត្តនៅក្នុងប្រទេសកម្ពុជា ក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam))[1] មានសេចក្តីសោមនស្សសូមដាក់ជូននូវគំនិតយោបល់ និងអនុសាសន៍ឆ្លើយតបទៅនឹង “សេចក្តីអំពាវនាវរបស់ អ.វ.ត.ក ស្នើសុំចូលរួមជាគំនិត” ដូចខាងក្រោម។ ជាបឋម មុនបង្ហាញគំនិតយោបល់ និងអនុសាសន៍ យើងខ្ញុំយល់ថាចាំបាច់ត្រូវគូសបញ្ជាក់អំពីបញ្ហាប្រឈមដែលយើងខ្ញុំយល់ថាជាការរារាំងដល់គំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងជនរងគ្រោះ ដែល អ.វ.ត.ក បានស្នើសុំគំនិតយោបល់។ ក្នុងករណីយើងខ្ញុំយល់មិនត្រូវអំពីបញ្ហាប្រឈមទាំងនេះ យើងខ្ញុំសូមគោរពស្នើសុំផ្តល់យោបល់កែសម្រួលតាមក្រោយ៖

ចំណុចទី១ យើងខ្ញុំយល់អំពីប្រភេទនៃគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងជនរងគ្រោះ ដែលត្រូវបានកំណត់ក្នុងក្របខណ្ឌមុខងារដូចមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធ ២ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប (A/RES/75/257B) (“សេចក្តីព្រាងកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា”)។ ចំណុចទី២ យើងខ្ញុំយល់ថា អ.វ.ត.ក ត្រូវមានតួនាទីជាអ្នកអនុវត្តសកម្មភាពទាំងនេះដោយផ្ទាល់។ ចំណុចទី៣ យើងខ្ញុំយល់ថា មុខងារទាំងនេះត្រូវតែសម្រេចដើម្បីឲ្យសមស្របនៅក្នុងរយៈពេល ៣ឆ្នាំ។ ទោះបីជាសេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប មិនបានលើកឡើងចំណុចនេះក៏ដោយ យើងខ្ញុំមើលឃើញបញ្ហាប្រឈមបន្ថែមទៀត ដែលអាចកើតឡើង ដោយសារវាទាក់ទងនឹងផលប្រយោជន៍របស់ម្ចាស់ជំនួយ និងលទ្ធភាពនៃថវិកា ដែលត្រូវចំណាយលើការអនុវត្តមុខងារទាំងនេះ។ ផ្អែកលើចំណុចទាំងនេះ AVPC សូមគោរពផ្តល់ជូននូវគំនិត និងអនុសាសន៍មួយចំនួនដូចខាងក្រោម៖

---

[1] មជ្ឈមណ្ឌលសន្តិសភាពអន្លង់វែងដំណើរការក្រោមមជ្ឈមណ្ឌលឯកសារកម្ពុជា។ *សម្រាប់ព័ត៌មានទូទៅ សូមមើល* មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង http://dccam.org/anlong-veng-peace-center។

Original EN: 01685655-01685656

ក្នុងចំណោមមុខងារដែលនៅសេសសល់ ដែល អ.វ.ត.ក នឹងអនុវត្ត គឺការផ្សព្វផ្សាយព័ត៌មានអំពី អ.វ.ត.ក ជូនដល់សាធារណជន។ យើងខ្ញុំជឿថា នៅពេល អ.វ.ត.ក ចាប់ផ្តើមរៀបចំបញ្ចប់ដំណើការសកម្មភាពរបស់ខ្លួន មុខងារមួយនេះអាចជាឱកាសមួយជួយពង្រឹងការងារពីមុនៗរបស់ អ.វ.ត.ក ពោលគឺ កិច្ចខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយជូនដល់សាធារណជនអំពីតុលាការ និងការងាររបស់ អ.វ.ត.ក ដែលកន្លងមកទទួលបាននូវការវាយតម្លៃខ្ពស់។ ក្រុមគោលដៅដែលយើងរំពឹងទុកគឺសាធារណជនកម្ពុជា។ ក៏ប៉ុន្តែ AVPC អាចមើលឃើញក្រុមគោលដៅជាក់លាក់ផ្សេងទៀតដែលអាចត្រូវបានកំណត់បន្ថែមនៅក្នុងសំណើសុំ និងសកម្មភាពលម្អិតនាពេលក្រោយ។ វិសាលភាពការងារអាចរួមបញ្ចូលការងារផ្សព្វផ្សាយជាច្រើនផ្សេងទៀតតាមបែបនវានុវត្តន៍ ដោយផ្អែកលើជំនាញ លទ្ធភាព និងសមត្ថភាពពិសេសរបស់អង្គការសង្គមស៊ីវិល ដែលដំណើរប្រតិបត្តិការនៅតាមតំបន់ដាច់ស្រយាលឆ្ងាយក្នុងប្រទេសកម្ពុជា ព្រមទាំងតាមមធ្យោបាយប្រព័ន្ធអនឡាញ និងប្រព័ន្ធផ្សព្វផ្សាយចម្រុះ ពោលគឺ ដោយប្រើប្រាស់ជំនាញរបស់អង្គការសង្គមស៊ីវិល ដែលមានស្រាប់ពីមុនមក ក៏ប៉ុន្តែគ្រាន់តែសម្រួចផ្តោតលើយុវជននៅតាមទីក្រុង និងទីប្រជុំជន។ គោលគំនិតទាំងនេះនឹងតម្រូវឱ្យដាក់ចេញជាសកម្មភាពលម្អិតបន្ថែមនៅក្នុងឯកសារទស្សនាទាន ឬ សំណើសុំជារួមតែម្តង ប៉ុន្តែយើងជឿជាក់ ថាការងារទាំងនេះនឹងមានភាពងាយស្រួលអនុវត្តជាងប្រសិនបើរៀបចំឱ្យសមស្របតាមក្របខណ្ឌពេលវេលា និងវិសាលភាពមុខងារដែលនៅសល់របស់ អ.វ.ត.ក។

មុខងារដែលនៅសេសសល់សំខាន់ទីពីរ ដែលត្រូវការពិចារណាគឺកិច្ចការពារជនរងគ្រោះ និងអ្នកនៅរស់ពីរបបនោះ។ ដោយសារតែ អ.វ.ត.ក ចាប់ផ្តើមដំណើរការបញ្ចប់ការងាររបស់ខ្លួន ជនរងគ្រោះ និងអ្នកនៅរស់ពីរបបនោះចាំបាច់ត្រូវទទួលបានការគាំទ្រ និងការពារ នៅក្នុងដំណាក់កាលចុងក្រោយនេះ។ ក្នុងរយៈពេលបីឆ្នាំនេះ ប្រសិនបើអាចយើងគួរអនុវត្តគម្រោងចំនួនពីរខុសគ្នា ប៉ុន្តែពាក់ព័ន្ធគ្នាទៅវិញទៅមក។ គម្រោងទីមួយ ផ្តោតលើការស្ទង់មតិជនរងគ្រោះ និងអ្នកនៅរស់ពីរបបនោះដើម្បីវាយតម្លៃមើលថាតើពួកគេយល់ថាបានទទួលការការពារត្រឹមកម្រិតណា តើពួកគេបានទទួលរងការគំរាមកំហែង ឬ រើសអើង ដោយសារតែបានចូលរួមក្នុងដំណើរការតុលាការដែរឬទេ ហើយសកម្មភាព ឬធនធានអ្វីខ្លះអាចជាប្រយោជន៍សម្រាប់ពួកគេនៅក្នុងអំឡុងពេល អ.វ.ត.ក ចាប់ផ្តើមដំណើរការបញ្ចប់សកម្មភាពរបស់ខ្លួននោះ។ ការស្ទង់មតិនេះមានសារៈសំខាន់ចំពោះគម្រោងទីពីរ ដែលមានបំណង ជាពិសេស ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៍ និងតម្រូវការរបស់ប្រជាជនប្រភេទនេះ ដោយសារវាទាក់ទងនឹងការចូលរួមរបស់ពួកគេនាពេលកន្លងមកនៅក្នុងដំណើរការតុលាការ។ ការស្ទង់មតិនេះមិនត្រឹមតែមានសារសំខាន់អាចជាការជូនព័ត៌មានអំពីសកម្មភាពរបស់សង្គមស៊ីវិល អ.ស.ប និងរដ្ឋាភិបាលក្នុងការគាំទ្រដល់ប្រជាជនប្រភេទនេះប៉ុណ្ណោះទេ វាក៏អាចផ្តល់ជាចក្ខុវិស័យសំខាន់ៗលើកិច្ចខិតខំប្រឹងប្រែងផ្សេងទៀតជុំវិញជនរងគ្រោះដោយអំពើហិង្សានៅក្នុងប្រទេសកម្ពុជា និងនៅជុំវិញពិភពលោក។ គម្រោងទី២ នឹងត្រូវអនុវត្ត ឬ ឆ្លើយតបទៅនឹងរបកគំហើញនៃការស្ទង់មតិ ដែលស្រដៀងគ្នាទៅនឹងមុខងារដែលនៅសេសសល់ខាងលើ ប្រសិនបើត្រូវបានយកមកអនុវត្តក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល។

ចំណុចចុងក្រោយ AVPC ក្រោមកិច្ចសម្របសម្រួលជាមួយអង្គការអាណាព្យាបាលរបស់ខ្លួន ពោលគឺ DC- Cam មានការចាប់អារម្មណ៍លើការងារលំហែទាំ ការថែរក្សា និងការគ្រប់គ្រងបណ្ណសាររបស់អង្គជំនុំជម្រះ ដើម្បីដាក់បញ្ចូលឯកសារ និងសម្ភារដែលបានធ្វើចំណាត់ថ្នាក់ឡើងវិញ។ AVPC មានគោលគំនិត និងអនុសាសន៍ជាច្រើនលើសកម្មភាពការងារទាំងនេះ ហើយ AVPC សូមស្វាគមន៍ប្រសិនបើទទួលបានឱកាសពិភាក្សាអំពីបញ្ហានេះបន្ថែមទៀត ទៅតាមការចង់បានរបស់ អ.វ.ត.ក។

ជាទីបញ្ចប់ យើងខ្ញុំសូមបញ្ជាក់ថា យើងខ្ញុំត្រៀមសហការជាមួយ អ.វ.ត.ក លើការងារពិគ្រោះយោបល់ ឬ កិច្ចសហប្រតិបត្តិការផ្សេងទៀត ដើម្បីជួយសម្រេចមុខងារនៅសេសសល់ដែល អ.វ.ត.ក រៀបចំបញ្ចប់ដំណើរការ។ ដំណើរការបញ្ចប់ការងាររបស់ អ.វ.ត.ក ត្រូវរៀបចំឱ្យបានគ្រប់ជ្រុងជ្រោយ ដោយត្រូវថ្លឹងថ្លែង និងផ្តោតសំខាន់លើប្រជាជន ដែលចាប់អារម្មណ៍ និងទទួលប្រយោជន៍ពីការងារ អ.វ.ត.ក ពោលគឺ ជនរងគ្រោះ និងអ្នកជាទីស្រលាញ់របស់ពួកគេ និងអ្នកនៅរស់រានពីរបបនោះ។ កេរដំណែល អ.វ.ត.ក មិនចាប់ផ្តើម និងបញ្ចប់ត្រឹមការងារផ្តល់យុត្តិធម៌ប៉ុណ្ណោះទេ ពោលគឺ កេរតំណែលនេះនឹងត្រូវបានកំណត់ក្នុងតម្លៃដូចគ្នា តាមរយៈផលវិជ្ជមាននៃ អ.វ.ត.ក មកលើប្រជាជនកម្ពុជា និង ភាគីច្រើននោះគឺមុខងារដែលនៅសល់របស់តុលាការមានតួនាទីសំខាន់ដូចគ្នានឹងការងារទាំងអស់ដែលតុលាការបានបំពេញរហូតមកដល់ពេលនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណ ថ្នាក់ដឹកនាំ អ.វ.ត.ក ចំពោះការពិនិត្យពិចារណាលើមតិយោបល់ និងអនុសាសន៍របស់យើងខ្ញុំ។ យើងខ្ញុំសូមស្វាគមន៍ និងត្រៀមចូលរួមពិភាក្សាលើមតិយោបល់ និងអនុសាសន៍ដែលបានដាក់ជូន ឬប្រធានបទផ្សេងទៀត ទាក់ទងនឹងការងារនេះបន្ថែមទៀត។

**បណ្ឌិត លី សុខឃាង**

**នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង**

*ក្រោមកិច្ចសហការជាមួយ*

**ផេង ពង្សរ៉ាស៊ី**

**នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង**

**ស៊ាង ចិន្តា**

**នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម**

**លី កុកឆាយ**

**នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ**

**ឡុង ដានី**

**មជ្ឈមណ្ឌលឯកសារកោះថ្ម**

# ជម្លោះនៅមីនដាណាវ (Mindanao)
# និង
# ក្ដីរំពឹងអំពីសន្តិភាព
# នៅប្រទេសហ្វីលីពីនភាគខាងត្បូង

**ដកស្រង់ចេញពីឯកសារមានចំណងជើងថា មីនដាណាវ៖ ក្ដីរំពឹងអំពីកិច្ចសន្ទនារវាងយុវជន អន្តរជាតិពន្ធុ និង ដំណោះស្រាយជម្លោះនៅប្រទេសហ្វីលីពីនភាគខាងត្បូង (Mindanao: A Perspective on Youth, Inter-Ethnic Dialogue and Conflict Resolution In the Southern Philippines) និពន្ធដោយ Susan D. Russell, Lina Davide-Ong, April Rica Gonzalez, Rey Ty, Nagasura T. Madale, និង Noemi A. Medina**

**រក្សាសិទ្ធិ © ឆ្នាំ២០០៤ ដោយ៖ មជ្ឈមណ្ឌលសិក្សាកិច្ចការនៅអាស៊ីអគ្នេយ៍ និង ការិយាល័យបណ្ដុះបណ្ដាលអន្តរជាតិ នៃសាកលវិទ្យាល័យ Northern Illinois**

**ក្រុង DeKalb រដ្ឋ Illinois ស.រ.អា**

**ACCESS Philippines គឺជាគម្រោងដែលបង្កើតឡើង និងផ្ដល់មូលនិធិដោយការិយាល័យផ្លាស់ប្ដូរបទពិសោធន៍រវាងពលរដ្ឋនិងពលរដ្ឋ ផ្នែកផ្លាស់ប្ដូរបទពិសោធន៍រវាងយុវជន ការិយាល័យកិច្ចការអប់រំ និងវប្បធម៌ ក្រសួងការបរទេសសហរដ្ឋអាមេរិក**

## ប្រវត្តិនៃការចរចាដោះស្រាយជម្លោះ និងសន្តិភាពជាផ្លូវការនៅប្រទេសហ្វីលីពីនភាគខាងត្បូង

ប្រទេសហ្វីលីពីន ដែលមានកោះចំនួនជាង ៧.០០០ មានប្រវត្តិដ៏យូរអង្វែង និងមានលក្ខណៈពិសេសក្នុងការរៀបចំប្រទេស នៅភាគខាងត្បូងនៃប្រជុំកោះ។ នៅចុងសតវត្សរ៍ទី១៨ និងទី១៩ បណ្តារដ្ឋដែលមានឥទ្ធិពលខ្លាំងបានលេចជារូបរាងឡើងនៅប្រជុំកោះ Sulu (នៅចំកណ្តាលកោះ Jolo) និងនៅប្រជុំកោះ Maguindanao (នៅចំកណ្តាលក្រុង Cotabato បច្ចុប្បន្ន នៅលើអាងទន្លេ Pulangi នៅ Mindanao)។ ក៏ប៉ុន្តែ សាសនាអ៊ីស្លាម និងគោលការណ៍គ្រប់គ្រងរដ្ឋបែបអ៊ីស្លាមបានចូលទៅតំបន់នេះតាំងពីសតវត្សរ៍ទី១៣ មកម្ល៉េះ។ បណ្តារដ្ឋទាំងនេះបានក្លាយជារដ្ឋគ្រប់គ្រងដោយស្តេចស៊ុលតង់ អស់រយៈពេលជាច្រើនសតវត្សរ៍ ដោយរាប់បញ្ចូលទាំងក្រុមភាសារបស់ជាតិពន្ធុជាច្រើននៅក្នុងការធ្វើជំនួញ និងសម្ព័ន្ធភាពរបស់ខ្លួន ដែលបានលាតសន្ធឹងរហូតដល់ទឹកដីម៉ាឡេស៊ី និងឥណ្ឌូនេស៊ីបច្ចុប្បន្នទៀតផង។ ឧត្តមគតិនៃសាសនាអ៊ីស្លាម និងការគ្រប់គ្រងរដ្ឋបែបជនជាតិដើមភាគតិចក៏បានជ្រៀតចូលទៅក្នុងតំបន់ Mindanao ក្នុងអំឡុងពេលនេះដែរ ហើយមានឥទ្ធិពលយ៉ាងធំធេងដល់ការបង្កើតជារដ្ឋបែបសហព័ន្ធមូស្លីមមួយទៀតនៅជិតទន្លេ Lanao។ ប្រព័ន្ធនយោបាយបែបប្រពៃណី Maranao ដែលគេហៅថាជា a pengampong ko ranao ឬ សសរស្តម្ភទាំងបួន គឺជាប្រព័ន្ធអំណាចបែបពហុភាគ (Madale 2003:41)។ ឥទ្ធិពលរបស់ពួកមូស្លីមពីតំបន់ទាំងនេះ ព្រមទាំងមកពីប្រទេសប្រ៊ុយណេ និង ប័រនេអូ (Borneo) បានពង្រីកអ៊ីស្លាមភាវូបនីយកម្មទៅភាគខាងជើងមកដល់សតវត្សរ៍ទី១៦ នៅទូទាំងតំបន់ Visayan ទាំងមូល និងរហូតដល់ក្រុងម៉ានីលទៀតផង។ ការចូលបញ្ចូលគ្នាផ្នែកជំនួញ ការវាយឆ្មក់ដោយពួកចោរសមុទ្រ និងការចាប់ទាសករ បានធ្វើឲ្យសេដ្ឋកិច្ចជាអន្តរជាតិ និងរវាងជាតិពន្ធុនៅបណ្តារដ្ឋភាគខាងត្បូងហ្វីលីពីនមានសន្ទុះយ៉ាងខ្លាំងក្លា និងបានប្រែក្លាយរដ្ឋទាំងនោះទៅជារដ្ឋបុរីដ៏មានឥទ្ធិពល។

នៅសតវត្សរ៍ទី១៦ អេស្ប៉ាញមានមហិច្ឆតាចង់បានផលប្រយោជន៍ពីជំនួញគ្រឿងទេសដែលរកប្រាក់ចំណេញបានច្រើននៅឥណ្ឌូនេស៊ីភាគខាងកើត និងមហិច្ឆតាក្នុងការបង្ហាញវត្តមានរបស់ខ្លួននៅអាស៊ីអគ្នេយ៍ បានជំរុញប្រទេសនេះឲ្យបង្កើតជារដ្ឋអាណានិគមមួយនៅហ្វីលីពីន។ អេស្ប៉ាញអាចកាន់កាប់ទឹកដីភាគច្រើននៅប្រទេសហ្វីលីពីនតែក្នុងរយៈពេលខ្លី ទោះបីការគ្រប់គ្រងបែបអាណានិគមមិនបានទទួលជោគជ័យនៅហ្វីលីពីនភាគខាងត្បូង ឬតំបន់ Cordillera នៅ Luzon ភាគខាងជើងក៏ដោយ។ ដូចនៅអាមេរិកឡាទីនដែរ អាណានិគមអេស្ប៉ាញមិនត្រឹមតែគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពនៅហ្វីលីពីនប៉ុណ្ណោះទេ តែក៏បានផ្តោតទៅលើការបញ្ចូលប្រជាជនក្រោមអាណានិគមឲ្យគោរពសាសនារ៉ូម៉ាំងកាតូលិកផងដែរ។ បណ្តារដ្ឋអ៊ីស្លាមនៅហ្វីលីពីនភាគខាងត្បូងមានស្ថាប័នរឹងមាំដែលអាចវាយទប់ទល់នឹងកម្លាំងយោធាអេស្ប៉ាញបាន ហេតុនេះហើយបានជារដ្ឋ Mindanao និងរដ្ឋ Sulu មិនស្ថិតនៅក្រោមអាណានិគមក្នុងរយៈពេល ៣០០ ឆ្នាំប្លាយមកនេះ។

ក្រោយពេលបញ្ចប់សង្គ្រាមរវាងអេស្ប៉ាញនិងអាមេរិក នៅឆ្នាំ១៨៩៨ អេស្ប៉ាញបានប្រគល់ប្រទេសហ្វីលីពីនទៅឲ្យសហរដ្ឋអាមេរិក តាមរយៈសន្ធិសញ្ញាទីក្រុងប៉ារីស៍។ ទោះបីរដ្ឋ Mindanao និងរដ្ឋ Sulu មិនស្ថិតនៅក្រោមអាណានិគមអេស្ប៉ាញក៏ដោយ តែរដ្ឋទាំងពីរនេះក៏បានបញ្ចូលទៅក្នុងសន្ធិសញ្ញានោះដែរ។ ជនជាតិហ្វីលីពីនអ៊ីស្លាមនៅភាគខាងត្បូងបានប្រឆាំងយ៉ាងខ្លាំងក្លា ដោយសំអាងថា ពួកគេជារដ្ឋឯករាជ្យ ហើយពេលនោះកងកម្លាំងយោធាអាមេរិកបានចូលប្រឡូកក្នុងសមរភូមិនានា ដើម្បីវាយបំបាក់ការតស៊ូប្រដាប់អាវុធ។ នៅឆ្នាំ១៩១៣ នៅសមរភូមិ Bud Bagsak សហរដ្ឋអាមេរិកបានទទួលជោគជ័យជាស្ថាពរ ក្នុងការនាំយករដ្ឋ Mindanao និងរដ្ឋ Sulu បញ្ចូលមកក្រោមអាណានិគមថ្មីរបស់អាមេរិកទៅលើប្រទេសហ្វីលីពីន។ ចាប់ពីពេលនោះមក អាមេរិកបានបង្កើតគោលនយោបាយជាច្រើន ដើម្បីធ្វើសមាហរណកម្មជនជាតិហ្វីលីពីនអ៊ីស្លាមទៅក្នុងសង្គមហ្វីលីពីនកាន់សាសនាគ្រីស្ទភាគច្រើន។ ទោះបីការខិតខំប្រឹងប្រែងទាំងនេះទទួលបានជោគជ័យខ្លះៗក៏ពិតមែន តែជនជាតិហ្វីលីពីនអ៊ីស្លាមជាច្រើនក្រុមនៅតែបន្តការតស៊ូប្រដាប់អាវុធដើម្បីផ្តាច់ខ្លួនចេញពីការគ្រប់គ្រងរបស់អាមេរិក និងក្រោយពេលហ្វីលីពីនបានក្លាយជារដ្ឋឯករាជ្យ។

នៅចុងទសវត្សរ៍១៩៦០ រណសិរ្សរំដោះជាតិម៉ូរ៉ូ (Moro National Liberation Front (MNLF)) ត្រូវបានបង្កើតឡើងដោយ Nur Misuari ហើយអំពើឧទ្ទាមកម្មប្រដាប់អាវុធបានផ្ទុះឡើងម្តងទៀតនៅ Mindanao។ មានបុព្វហេតុជាច្រើនដែលនាំឲ្យមានអំពើឧទ្ទាមកម្មនេះកើតឡើង តែប្រការសំខាន់គឺមហិច្ឆតាចង់ក្លាយជារដ្ឋឯករាជ្យដាច់ដោយឡែក ឬហៅថា Bangsa Moro ដែលជនជាតិហ្វីលីពីនអ៊ីស្លាមអាចទទួលបាន និងគ្រប់គ្រងទៅលើសេវាសង្គម ដើម្បីឲ្យពួកគេអាចទទួលបានផលប្រយោជន៍យ៉ាងពិតប្រាកដពីការអភិវឌ្ឍសេដ្ឋកិច្ចនៅរដ្ឋ Mindanao។ ពួកគេក៏ចង់មានសមត្ថភាពការពារទឹកដីដូនតាដែលកាន់កាប់ដោយជនជាតិហ្វីលីពីនកាន់សាសនាគ្រីស្ទ ឬក្រុមហ៊ុនពហុជាតិ និងអ្នកតាំងទីលំនៅ ព្រមទាំងចង់រៀបចំការរស់នៅតាមបែបអ៊ីស្លាម។

ភាពគ្មានសមធម៌ និងអយុត្តិធម៌សង្គមដែលជនជាតិហ្វីលីពីនម៉ូរ៉ូ បានជួបប្រទះ និងជាចុងក្រោយបានបង្កើតជាអំពើឧទ្ទាមកម្មទាំងកំហឹង គឺកើតឡើងដោយសារគោលនយោបាយបញ្ចូលសាសនារបស់អាមេរិក និងរដ្ឋាភិបាលជាតិហ្វីលីពីន។ នៅដើមសតវត្សរ៍ទី២០ បណ្តាអ្នកកាន់អំណាចនៅក្រុងម៉ានីល នៅតែចាត់ទុកថា រដ្ឋ Mindanao ជា “រណសិរ្សចុងក្រោយ” ជាកោះដែលមានទឹកដីធំធេង និងធនធានធម្មជាតិដែលមិនទាន់បានទទួលផល។ ដោយសង្ឃឹមថានឹងអាចធ្វើសមាហរណកម្មប្រជាជននៅរដ្ឋ Mindanao និងរដ្ឋ Sulu ទៅក្នុងសង្គមហ្វីលីពីនទាំងមូល ហើយសង្ឃឹមថានឹងអាចទទួលផលអំពីធនធានទាំងនេះ រដ្ឋាភិបាលអាណានិគមអាមេរិកបានផ្តួចផ្តើមឲ្យមានគោលនយោបាយផ្គត់ផ្គង់ខ្លួនឯង ក្នុងគោលបំណងទាក់ទាញឲ្យអ្នកតាំងទីលំនៅពីតំបន់ដែលមានមនុស្សរស់នៅកកកុញនៃភាគកណ្តាល និងភាគខាងជើងហ្វីលីពីន ឲ្យទៅតាំងទីលំនៅនៅហ្វីលីពីនភាគខាងត្បូង

ដែលមានប្រជាជនតិចតួច។ អ្នករៀបចំគោលនយោបាយអាមេរិក ហើយក្រោយមកគឺអ្នករៀបចំគោលនយោបាយហ្វីលីពីន យល់ឃើញថា ការច្របាច់បញ្ចូលគ្នារវាងជនជាតិនិងជនជាតិនឹងបញ្ចៀបគោលការណ៍តម្លៃវប្បធម៌ជាតិទៅក្នុងតំបន់នេះបាន និងអាចកាត់បន្ថយបាននូវការតស៊ូប្រដាប់អាវុធ នាពេលអនាគតបាន។ ផលប្រយោជន៍របស់អាមេរិកក្នុងការជំរុញឲ្យមានការបញ្ចូលសាសនា ក៏ដោយសារតែចាំបាច់ត្រូវដោះស្រាយនៃការតវ៉ាប្រឆាំងពីសំណាក់អ្នកជួលដី និងអ្នកទទួលផលពីកសិកម្មនៅតំបន់ Luzon ភាគកណ្តាល ដែលមានភាពក្រីក្រ ភាពមិនស្មើគ្នា និងអសមត្ថភាពរបស់អាមេរិកក្នុងការអនុវត្តនូវកំណែទម្រង់ដីធ្លី ជាបុព្វហេតុចម្បងដែលនាំឲ្យមានការបះពោរពីពួកកុម្មុយនីស្ត។ ទោះបី ក្នុងអំឡុងសម័យអាណានិគមអាមេរិក ការផ្លាស់ទីលំនៅពីភាគខាងជើងទៅកាន់ Mindanao មានចំនួនតិចតួចក្តី តែចំនួននេះបានហក់ឡើងខ្ពស់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ក្រោយចប់សង្គ្រាមលោកលើកទី២។

នៅដើមទសវត្សរ៍១៩៧០ ការធ្វើចំណាកស្រុកនៃជនជាតិហ្វីលីពីនកាន់សាសនាគ្រឹស្ទទៅ Mindanao បានបង្កើតនូវទិដ្ឋភាពសង្គមមួយដែលធ្វើឲ្យជនជាតិហ្វីលីពីនម៉ូរ៉ូ និងជនជាតិហ្វីលីពីនជាក្រុមជនជាតិដើមភាគតិច (Lumad) ក្លាយជាភាគតិចនៅក្នុងទឹកដីកំណើតរបស់ខ្លួន[1]។ អំពើហិង្សាបានកើតឡើងរវាងពួកម៉ូរ៉ូនិងពួកគ្រឹស្ទសាសនិក ព្រមទាំងរវាងពួកគ្រឹស្ទសាសនិកនិងពួក Lumads ក្លាយជារឿងធម្មតានៅ Mindanao ទៅលើសិទ្ធិចំពោះទឹកដីដូនតា ព្រមទាំងការបាត់បង់អំណាចនយោបាយរបស់ datu និងអ្នកក្រោមឱវាទ។ ពួកម៉ូរ៉ូ និងពួក Lumads យល់ថា ពួកគេមិនត្រឹមតែបាត់បង់ទឹកដីដូនតា និងធនធានផលិតកម្មផ្សេងទៀតប៉ុណ្ណោះទេ តែពួកគេក៏បាត់បង់អត្តសញ្ញាណវប្បធម៌របស់ខ្លួនផងដែរ។ ក្នុងអំឡុងពេលនេះហើយដែលរដ្ឋាភិបាលជាតិបានបង្ហាញឆន្ទៈមោះមុតថា ជនជាតិហ្វីលីពីនមូស្លីម (ម៉ូរ៉ូ) ដែលមានជាតិពន្ធុចម្រុះជា "សាសនា" ភាគតិច ចំណែកឯជនជាតិហ្វីលីពីនមិនមែនមូស្លីម មិនមែនគ្រិស្ទសាសនិក (Lumad) ជា "វប្បធម៌ភាគតិច"។

ជាអកុសល ពីដំបូង រដ្ឋាភិបាលនៅក្រុងម៉ានីលបានឆ្លើយចំពោះអំពើឧទ្ទាមកម្មរបស់ពួករណសិរ្សរំដោះជាតិម៉ូរ៉ូ ដោយប្រើកម្លាំងយោធា ហើយការវាយប្រយុទ្ធគ្នាបានផ្ទុះឡើងនៅ Mindanao។ ការប្រកាសច្បាប់អាជ្ញាសឹកនៅឆ្នាំ១៩៧២ ដោយអតីតប្រធានាធិបតី Ferdinand Marcos ក៏បានបង្កឲ្យមានការប្រឈមមុខដាក់គ្នាផ្នែកយោធានៅក្នុងតំបន់នោះកាន់តែខ្លាំងឡើងៗ។ មានការខិតខំប្រឹងប្រែងមួយចំនួនក្នុងការបញ្ចប់ជម្លោះ រួមមានការបង្កើតអាជ្ញាធរអភិវឌ្ឍន៍ភាគខាងត្បូងហ្វីលីពីន និងអន្តរាគមន៍ពីអង្គការសន្និសីទអ៊ីស្លាម និងភាគីអន្តរ

---

[1] Lumad ជាពាក្យដែលយកមកប្រើប្រាស់នាពេលថ្មីៗនេះ ដោយសំដៅជារួមទៅក្រុមមិនមែនមូស្លីម/មិនមែនគ្រិស្ទសាសនិក ជួនកាលគេហៅថា "សហគមន៍វប្បធម៌" នៅ Mindanao, Basilan, Tawitawi និង Sulu ទាំងមូល។

ជាតិផ្សេងៗទៀត។ ក៏ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងទាំងនេះទទួលបានលទ្ធផលតិចតួច រហូតដល់មានអន្តរាគមន៍ពីប្រធានាធិបតីលីប៊ី Gaddafi។

នៅឆ្នាំ១៩៧៦ កិច្ចព្រមព្រៀង Tripoli ត្រូវបានចុះហត្ថលេខានៅប្រទេសលីប៊ីរវាងរដ្ឋាភិបាលហ្វីលីពីន និងពួក MNLF។ កិច្ចព្រមព្រៀងនេះបានផ្តល់នូវស្វ័យភាពផ្នែកនយោបាយដល់ខេត្តចំនួន ១៣ នៅ Mindanao, Sulu និង Palawan ភាគខាងត្បូង ដែលជនជាតិហ្វីលីពីនម៉ូស្លីមចាត់ទុកជាទឹកដីកំណើតជាប្រពៃណី ឬជាភូមិភាគនៃឥទ្ធិពលរបស់ខ្លួន។ កិច្ចព្រមព្រៀងនេះក៏បានផ្តល់ការលើកលែងទោសដល់ពួកឧទ្ទាមផងដែរ។ ក៏ប៉ុន្តែ ប្រធានាធិបតី Marcos នាពេលនោះបានទទូចឲ្យបោះឆ្នោតធ្វើប្រជាមតិ ដើម្បីសម្រេចថាតើប្រជាជននៅមូលដ្ឋានគាំទ្រដល់ស្វ័យភាព ឬទេ តែពួក MNLF និងអ្នកក្រោមឱវាទបានធ្វើពហិកាមិនចូលរួមការបោះឆ្នោតនោះ។ មានតែខេត្តចំនួន ៤ ប៉ុណ្ណោះដែលបានបោះឆ្នោតគាំទ្រស្វ័យភាព ហេតុនេះតំបន់ស្វ័យភាពដាច់ដោយឡែកត្រូវបានបង្កើតឡើងនៅតំបន់ ៩ និងតំបន់ ១២។ រដ្ឋាភិបាលស្វយ័តទាំងនេះមានភាពទន់ខ្សោយ គ្មានអំណាចនយោបាយ និងខ្វះថវិកា (May 2002:3)។

ការបរាជ័យមិនទទួលបានស្វ័យភាពពិតប្រាកដក៏នាំឲ្យមានការបែកបាក់គ្នាដែរនៅក្នុង MNLF ដែលមានការខ្វែងយោបល់គ្នារវាងមេដឹកនាំក្រុមអំបូរភាសា និងក្រុមនយោបាយ។ នៅឆ្នាំ១៩៧៧ Hashim Salamat រួមជាមួយក្រុម Maguindanao-Iranun បានបង្កើតរណសិរ្សរំដោះអ៊ីស្លាមម៉ូរ៉ូ។ Nur Misuari ដែលជាអំបូរ Tausug-Samal ស្ថិតនៅជាមេដឹកនាំ MNLF ដែលទទួលស្គាល់ដោយរដ្ឋាភិបាល។ ក្រុមទីពីរដែលភាគច្រើនជាអំបូរ Maranao ជាក្រុមនិយមកែទម្រង់ MNLF ក៏បានបះបោរស្រដៀងគ្នាដែរ ប្រឆាំងនឹងការដឹកនាំរបស់ Nur Misuari។

នៅឆ្នាំ១៩៨៦ នៅពេលលោកស្រី Corzaon Aquino ក្លាយជាប្រធានាធិបតីហ្វីលីពីន រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានតាក់តែងឡើង ដែលបង្កើតឲ្យមានតំបន់ស្វយ័តថ្មីមួយគឺ Mindanao មូស្លីម (ព្រមទាំងតំបន់ស្វយ័ត Cordillera នៅភាគខាងជើង Luzon ជាកន្លែងដែលពួកបះបោរកុម្មុយនីស្តកំពុងវាយប្រយុទ្ធនឹងកងកម្លាំងរដ្ឋាភិបាល)។ ពួក MNLF មិនបានចូលរួមក្នុងការបង្កើតតំបន់ស្វយ័ត Mindanao មូស្លីម (ARMM) ទេ ហើយក្រោយមកមានការធ្វើប្រជាមតិម្តងទៀតដើម្បីទទួលបានការគាំទ្រពីប្រជាជនឲ្យចូលរួម ARMM មកពីខេត្តតែ ៤ ប៉ុណ្ណោះក្នុងចំណោមខេត្តទាំង ១៣ និងពុំមានក្រុងចូលរួមទេ (May 2002:3)។ ជម្លោះនៅតែបន្ត ហើយ ARMM នៅតែទន់ខ្សោយផ្នែកអំណាចនយោបាយ និងថវិកា។

នៅឆ្នាំ១៩៩២ ប្រធានាធិបតី Fidel Ramos បានធ្វើការចរចាជាថ្មីជាមួយ Nur Misuari និងពួក MNLF ដោយមានជំនួយពីប្រទេសលីប៊ី ព្រមទាំងអង្គការសន្និសីទអាហ្វ្រិក។ នៅឆ្នាំ១៩៩៦ ភាគីទាំងអស់សម្រេចបាន

កិច្ចព្រមព្រៀងមួយដែលបង្កើតតំបន់ពិសេសនៃសន្តិភាព និងអភិវឌ្ឍន៍ (Special Zone of Peace and Development (SZOPAD)) មួយ និងក្រុមប្រឹក្សាទទួលបន្ទុកសន្តិភាព និងអភិវឌ្ឍន៍ហ្វីលីពីនភាគខាងត្បូង (Southern Philippines Council for Peace and Development (SPCPD))។ តំបន់ពិសេស SZOPAD រួមមានខេត្តចំនួន ១៤ (បន្ថែមខេត្តមួយ) និងទីក្រុងចំនួន ៩ ដែលត្រូវបានទទួលស្គាល់នៅក្នុងកិច្ចព្រមព្រៀង Tripoli ហើយនឹងផ្តោតទៅលើកិច្ចខិតខំប្រឹងប្រែងឲ្យមានសន្តិភាព និងអភិវឌ្ឍន៍។ ក្រុមប្រឹក្សា SPCD គឺជាស្ថាប័ននីតិបុគ្គលដែលរួមមានប្រធានមួយរូប អនុប្រធានមួយរូប និងសមាជិកបីរូប ដែលសមាជិកម្នាក់តំណាងមកពីគ្រីស្ទសាសនា ម្នាក់ទៀតតំណាងមកពីជនជាតិម៉ូរ៉ូ និងម្នាក់ទៀតតំណាងមកពី “សហគមន៍វប្បធម៌” (Lumad)។ ក្រុមប្រឹក្សានេះមានជំនួយពី Darul Iftah (ក្រុមប្រឹក្សាពិគ្រោះយោបល់ផ្នែកសាសនា) ដែលតែងតាំងដោយប្រធាន។ កិច្ចព្រមព្រៀងនេះក៏បានបង្កើតឲ្យមានសភាពិគ្រោះយោបល់ដែលមានសមាជិកចំនួន ៨១ រូប រួមមានប្រធានក្រុមប្រឹក្សា SPCD ជាប្រធាន អភិបាល និងអភិបាលរងនៃតំបន់ស្វយ័ត ARMM អភិបាលខេត្តទាំង ១៤ និងអភិបាលក្រុងទាំង ៩ នៃតំបន់ពិសេស SZOPAD សមាជិក MNLF ចំនួន ៤៤ រូប និងតំណាងចំនួន ១១ រូប ដែលត្រូវបានតែងតាំងដោយអង្គការមិនមែនរដ្ឋាភិបាល (NGO) និងអង្គការប្រជាជន។ មុខងាររបស់សភាពិគ្រោះយោបល់គឺដើរតួនាទីជាវេទិកាដែលស្តាប់បញ្ហា និងដោះស្រាយជម្លោះ រៀបចំសវនាការជាសាធារណៈ និងផ្តល់យោបល់ទៅក្រុមប្រឹក្សា SPCPD និងផ្តល់អនុសាសន៍ជាគោលនយោបាយនានាជូនប្រធានាធិបតី (May 2002:5 សូមមើលផងដែរ Rodil 2000)។

កិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩៦ នេះ បានផ្តល់ការងារដល់ពួកឧទ្ទាម MNLF (កងទ័ពម៉ូរ៉ូ Bangsa) នៅក្នុងជួរនគរបាលជាតិ កងកម្លាំងប្រដាប់អាវុធហ្វីលីពីន និងកងកម្លាំងពិសេសពាក់ព័ន្ធផ្សេងទៀត។ ចំពោះអ្នកដែលមិនបានបញ្ចូលតាមវិធីនេះ ពួកគេនឹងទទួលបានជំនួយផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម វប្បធម៌ និងអប់រំ។ កិច្ចព្រមព្រៀងនេះក៏ចែងឲ្យមានក្រុមប្រឹក្សាប្រតិបត្តិ សភានីតិប្បញ្ញត្តិ និងប្រព័ន្ធរដ្ឋបាលថ្មីសម្រាប់តំបន់ស្វយ័ត ARMM ដែលមានអំណាចនីតិប្បញ្ញត្តិទៅលើវិស័យស្វយ័តនានាដែលបានព្រមព្រៀង ដូចជា ច្បាប់ Shariah និងមានតំណាងនៅក្នុងរដ្ឋាភិបាលថ្នាក់ជាតិ រួមមាន គណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សាសន្តិសុខជាតិ។ មានការផ្តល់ជំនួយពិសេសសម្រាប់សាលាមូស្លីម (madaris) ដូចជា ការទទួលស្គាល់ការណែនាំនៃភាសាអារ៉ាប់ និងតម្លៃសីលធម៌អ៊ីស្លាម ជាផ្នែកនៃចំណូលស្នូលរបស់ពួកគេ។ ក្រោយមក Nur Misuari ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សា SPCPD ហើយចុងក្រោយ គាត់ត្រូវបានបោះឆ្នោតជាអភិបាលតំបន់ស្វយ័ត ARMM។ បទប្បញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងបានកំណត់ឲ្យមានការធ្វើប្រជាមតិម្តងទៀតនៅឆ្នាំ២០០៨។ តែការធ្វើប្រជាមតិមិនត្រូវបានរៀបចំទេរហូតដល់ឆ្នាំ២០០១។ មានតែខេត្តចំនួន ៥ និងក្រុង ១ ប៉ុណ្ណោះដែលបានបោះឆ្នោតគាំទ្រឲ្យចូល

រួមនៅក្នុងតំបន់ស្វយ័ត ARMM ដែលបង្កើតថ្មី។ Nur Misuari មិនបានជាប់ឆ្នោតជាថ្មីជាអភិបាលទៀតទេ ហើយក្រោយមក គាត់ក៏បានធ្វើការវាយប្រហារប្រដាប់អាវុធទៅលើកងទ័ពជាតិ។ ក្រោយមក គាត់ត្រូវបានរដ្ឋាភិបាលម៉ាឡេស៊ីចាប់ខ្លួន និងបញ្ជូនទៅឲ្យរដ្ឋាភិបាលហ្វីលីពីន នៅពេលគាត់ព្យាយាមគេចខ្លួនមកខេត្ត Sabah របស់ម៉ាឡេស៊ី នៅលើកោះ Borneo ដើម្បីគេចចេញពីការចាប់ខ្លួន។ នាពេលបច្ចុប្បន្ន គាត់កំពុងជាប់ឃុំឃាំងរង់ចាំការជំនុំជម្រះទោសពីបទឧទ្ទាមកម្ម (May 2003:8)។

ក្តីសង្ឃឹមដែលកើតចេញពីកិច្ចព្រមព្រៀងនេះមិនមានភាពយូរអង្វែងទេ។ មេដឹកនាំគ្រីស្ទសាសនិកនៅ Mindanao បានជំទាស់ទៅនឹងស្វ័យភាព និងចំណុចផ្សេងៗទៀតនៅក្នុងកិច្ចព្រមព្រៀង។ ហេតុនេះ សំណៅចុងក្រោយនៃបទបញ្ញាប្រតិបត្តិបានកម្រិតយ៉ាងតឹងរ៉ឹងនូវលទ្ធភាពរបស់ក្រុមប្រឹក្សា SPCPD ក្នុងការផ្តល់អនុសាសន៍ទៅលើគោលនយោបាយ ឬគ្រប់គ្រងជាក់ស្តែងទៅលើទិដ្ឋភាពនៅក្នុងរដ្ឋាភិបាល និងបានដកសមាជិក MNLF ទាំង ៤៤ រូបចេញពីសភាពិគ្រោះយោបល់។ សន្តិភាពមានភាពផុយស្រួយ ដោយសារពួក MILF ចាប់ផ្តើមប្រមូលកម្លាំងបន្ថែមទៀត ដោយមានការសង្ស័យថា រដ្ឋាភិបាលថ្នាក់ជាតិពុំមានការប្តេជ្ញាចិត្តជាក់ស្តែងក្នុងការរក្សាសន្តិភាព ឬផ្តល់ស្វ័យភាព។ ការណ៍ដែលថាប្រជាជនអំបូរម៉ូរ៉ូ (ឬ Lumad) បានទទួលផលប្រយោជន៍ដ៏តិចតួចពីការអភិវឌ្ឍសង្គម ឬសេដ្ឋកិច្ចជាក់ស្តែង និងការពិតដែលរដ្ឋាភិបាលមិនបានគោរពតាមការសន្យានោះ នាំឲ្យជនជាតិហ្វីលីពីនម៉ូរ៉ូជាច្រើននាក់លែងមានក្តីសង្ឃឹមថា នឹងមានអនាគតបវររុងរឿង តាមរយៈការចរចាជាមួយរដ្ឋាភិបាលថ្នាក់ជាតិតទៅទៀត។ ជម្លោះនៅតែបន្តកើតមាន ទោះបីកម្មវិធីជំនួយពីបណ្តាម្ចាស់ជំនួយជាច្រើនពីអង្គការសហប្រជាជាតិបានជួយបង្កើតសហគមន៍សន្តិភាព និងអភិវឌ្ឍន៍ជាច្រើនដែលបញ្ចូលប្រជាជនអំបូរ Lumad និងមិនមែនមូស្លីម ហើយសហគមន៍ទាំងនោះដឹកនាំដោយអតីតមេដឹកនាំនៃពួក MNLF ក៏ដោយ។

នៅឆ្នាំ២០០០ ការកើនឡើងនៃការវាយប្រហារពីសំណាក់កងកម្លាំងរំដោះអ៊ីស្លាមម៉ូរ៉ូទៅលើសហគមន៍មិនមែនមូស្លីមនៅ Cotabato ខាងជើង និង Maguindanao នាំឲ្យប្រធានាធិបតី Joseph Estrada បើកការវាយប្រហារយោធាហ្វីលីពីន និងបានប្រកាសសង្គ្រាមជាថ្មីប្រឆាំងនឹងពួកគេ។ ប្រការនេះនាំឲ្យប្រជាជនរាប់សែននាក់ក្លាយជាជនភៀសសឹក និងមានមនុស្សស្លាប់រាប់ពាន់នាក់។ ពុំមានតួលេខជាក់លាក់ពីការស្លាប់ទេ។ នៅឆ្នាំ១៩៩៦ កងកម្លាំងប្រដាប់អាវុធហ្វីលីពីននិយាយថា ក្នុងរយៈពេល ២៦ ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៧០ មក មានប្រជាជនជាង ១០០.០០០ នាក់ត្រូវបានសម្លាប់នៅក្នុងជម្លោះនៅ Mindanao។ ក្នុងចំណោមនោះ ៣០ ភាគរយ មកពីភាគីរដ្ឋាភិបាល ៥០ ភាគរយ ជាពួកឧទ្ទាម និង ២០ ភាគរយ ជាប្រជាជនស៊ីវិល។ មានការប៉ាន់ស្មានថា ប្រជាជនស៊ីវិល និងទាហានប្រមាណ ៥៥.០០០ នាក់បានទទួលរងរបួស តែពុំមានព័ត៌មានពីចំនួនអ្នករងរបួសពីភាគីពួកឧទ្ទាមទេ។ ក្នុងអំឡុងរយៈពេល ២៦ឆ្នាំ កងកម្លាំងប្រដាប់អាវុធបានចំណាយថវិកាអស់ចំនួន ៧៣ ពាន់លាន

ប៉េសូទៅលើសង្គ្រាម ឬប្រហែល ៤០ ភាគរយនៃថវិកាជាតិប្រចាំឆ្នាំរបស់ខ្លួន។ បណ្ឌិត Rudy Rodil ជាសមាជិកក្រុមប្រឹក្សាចរចារបស់រដ្ឋាភិបាលជាមួយពួក MNLF និងបាននិពន្ធសៀវភៅមានចំណងជើងថា "Kalinaw Mindanaw: the Story of the GRP-MNLF Peace Process, 1975-1996" បានកត់សម្គាល់ថា ការចំណាយក្នុងការចរចាស្វែងរកសន្តិភាពជាមួយពួក MNLF ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៦ មិនដល់ ៦០ លានប៉េសូ។ នៅឆ្នាំ២០០១ ក្រោយពេលរដ្ឋការលោក Estrada ប្រកាសសង្គ្រាមជាថ្មីប្រឆាំងពួក MILF រដ្ឋាភិបាលនិយាយថា យ៉ាងហោចថវិកាចំនួន ៦ ពាន់លានប៉េសូត្រូវបានចំណាយនៅក្នុងសង្គ្រាមនៅឆ្នាំ២០០០ ជាការចំណាយលើសមួយពាន់លានប៉េសូ ដែលរដ្ឋាភិបាលយកទៅសាងសង់សាលារៀននៅទូទាំងប្រទេស។ ថវិកាចំនួន ១៦ លានប៉េសូផ្សេងទៀត ត្រូវបានចំណាយទៅលើជំនួយសង្គ្រោះដល់ប្រជាជនភៀសសឹក និងអ្នកភៀសខ្លួន។

នៅឆ្នាំ២០០២ លោក Paul Dominguez ជាជំនួយការប្រធានាធិបតីទទួលបន្ទុកអភិវឌ្ឍន៍តំបន់ បានធ្វើការដកស្រង់សំដីនៅក្នុងការរកឃើញបឋមពីការសិក្សារបស់ធនាគារពិភពលោក ដែលបានបង្ហាញថា ការចំណាយផ្នែកសេដ្ឋកិច្ចតែមួយ ដោយមិនរាប់បញ្ចូលនូវការចំណាយផ្នែកសង្គម ទៅលើជម្លោះគ្មានទីបញ្ចប់នៅ Mindanao អាចមានទំហំថវិកាយ៉ាងហោចណាស់ ២ ពាន់លានដុល្លារអាមេរិកក្នុងរយៈពេល ១០ ឆ្នាំទៅមុខទៀត[2]។ តួលេខនោះប្រហាក់ប្រហែល ១០៨ ពាន់លានប៉េសូសម្រាប់រយៈពេល ១០ ឆ្នាំ ឬ ១០,៨ ពាន់លានប៉េសូក្នុងមួយឆ្នាំ។ តួលេខទាំងនេះត្រូវបានគណនាដោយពួកសេដ្ឋវិទូអន្តរជាតិដែលយកតាមគំរូផ្សេងៗទៀត ដូចជានៅប្រទេសនីការ៉ាហ្គាជាដើម ហើយពួកគេមានប្រៀបប្រដូចជម្លោះនៅ Mindanao ទៅនឹងសង្គ្រាមគ្មានទីបញ្ចប់ដែលកើតឡើងតាមកាលកំណត់។ ហើយមានការបង្ហាញថា និងតំបន់ស្វយ័ត ARMM ទាំងមូល និងដោយឡែកនៅ Mindanao ភាគនិរតី មានការធ្លាក់ចុះដល់ចំណុចក្រោមគេនៅទូទាំងប្រទេស ពាក់ព័ន្ធនឹងសេវាសង្គមកិច្ច រួមមាន ការអប់រំ ហេដ្ឋារចនាសម្ព័ន្ធ និងប្រាក់ចំណូលរបស់ប្រជាជន[3]។

ស្ថានភាពកាន់តែអាក្រក់ទៅទៀត គឺក្រោយពីសង្គ្រាមនៅឆ្នាំ២០០០ ថវិកាជាតិហ្វីលីពីនបានកើនពី ៧២៥ ពាន់លានប៉េសូនៅឆ្នាំ២០០១ ទៅ ៧៨០,៧៩ ពាន់លានប៉េសូនៅឆ្នាំ២០០២ និង ៨០២,២ ពាន់លានប៉េសូនៅឆ្នាំ២០០៣។ ក៏ប៉ុន្តែថវិកាដែល Mindanao ទទួលបានពីថវិកាជាតិ បានធ្លាក់ចុះពី ១៣,៩ ភាគរយនៅឆ្នាំ២០០១ មកត្រឹម ១១,៩ ភាគរយនៅឆ្នាំ២០០២។ នៅឆ្នាំ២០០៣ Mindanao បានទទួលថវិកាត្រឹមតែ ១០,៥៥

---

[2] សូមមើល៖ http://www.mindanews.com/2003/03/12pep-cost.html ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤។

[3] សូមមើល៖ http://www.mindanews.com/2003/03/12pep-cost.html ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤។

ភាគរយប៉ុណ្ណោះពីថវិកាជាតិ។ ហេតុនេះ ទោះបីការចំណាយផ្នែកសេដ្ឋកិច្ចដោយសារសង្គ្រាមនៅ Mindanao មានការកើនឡើងខ្ពស់ និងមានការបាត់បង់ជីវិត ហើយការផ្លាស់ទីលំនៅប្រជាជនមានភាពធំធេងក៏ដោយ តែតំបន់ភាគខាងត្បូងហ្វីលីពីនទាំងមូល ត្រូវទទួលបន្ទុកបន្ថែមទៀត ដោយសារកាត់បន្ថយផលប្រយោជន៍ពីការទទួលថវិកាប្រចាំឆ្នាំពីរដ្ឋាភិបាលថ្នាក់ជាតិ។

ប្រហែលមួយផ្នែក ដោយសារការរកឃើញទាំងនេះហើយបានជាលោកស្រីប្រធានាធិបតី Gloria Macapagal-Arroyo ចាប់ផ្តើមបង្កើតកិច្ចខិតខំប្រឹងប្រែងចរចាស្វែងរកសន្តិភាពជាថ្មីជាមួយពួក MILF។ គិតមកត្រឹមនឹងពេលនេះ គឺខែតុលា ឆ្នាំ២០០៤ ក្រុមការងារតាមដានដំណើរការសន្តិភាពដែលដឹកនាំដោយម៉ាឡេស៊ីបានទៅដល់ Mindanao និងរំពឹងថានឹងស្ថិតនៅទីនោះរយៈពេលមួយឆ្នាំ។ ការចរចាស្វែងរកសន្តិភាពជាផ្លូវការរវាងរដ្ឋាភិបាលហ្វីលីពីន និងពួក MILF ដែលផ្តួចផ្តើមដោយប្រទេសម៉ាឡេស៊ី និងការចូលរួមពីតំណាងមកពីអង្គការសន្និសីទអ៊ីស្លាម ត្រូវបានរំពឹងថានឹងបន្តទៅទៀតនៅប្រទេសម៉ាឡេស៊ី ក្នុងខែវិច្ឆិកា ក្រោយពេលចប់រដូវបុណ្យតមអាហារបែបអ៊ីស្លាម Ramadan។ គោលបំណងនៃការចរចាគឺដើម្បីពិភាក្សារកដំណោះស្រាយទូលំទូលាយមួយ ដែលពាក់ព័ន្ធដល់ទិដ្ឋភាពផ្សេងៗជាច្រើននៃការព្រួយបារម្ភ ចំពោះប្រជាជនហ្វីលីពីនម៉ូរ៉ូ រួមមានស្វ័យភាពនៃការគ្រប់គ្រង ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ច្បាប់អ៊ីស្លាម shari'ah និងការអប់រំ កម្មវិធីសិក្សាពហុវប្បធម៌ និងការទទួលស្គាល់ទឹកដីដូនតានៅតំបន់ស្វយ័ត ARMM (Basilan, Lanao del Sur, Maguindanao, Sulu, Tawi-Tawi, និងក្រុង Marawi)។ មេដឹកនាំនៃពួក MILF គឺលោក Ebrahim Murad បានថ្លែងជាសាធារណៈថា សមាជិកក្នុងក្រុមគាត់ចំនួន ១២.០០០ នាក់បានរួបរួមគ្នា និងប្តេជ្ញាចិត្តចូលរួមចរចាជាមួយរដ្ឋាភិបាលជាតិហ្វីលីពីន ទៅលើបញ្ហាមួយចំនួនដែលបានព្រមព្រៀងជាមុន ក្នុងការដោះស្រាយជម្លោះ។

### បរិបទភាសាជាតិពន្ធុត្រីភាគី និងបុព្វហេតុជាឫសគល់ជម្លោះ

ដោយគូសបញ្ជាក់នូវមូលដ្ឋាននៃជម្លោះនៅ Mindanao គឺជាការតស៊ូក្នុងចំណោមប្រជាជនម៉ូរ៉ូ និងជនជាតិដើមភាគតិចមិនមែនមូស្លីម ដែលចង់ឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកាន់តែប្រសើរ ការទទួលស្គាល់ដោយស្មើភាព និង ការគាំពារដល់អត្តសញ្ញាណវប្បធម៌ និងសាសនារបស់ខ្លួន និងយុត្តិធម៌សង្គម។ បណ្ឌិត Rudy Rodil បញ្ចេញមតិអំពីបញ្ហានយោបាយ និងជាតិពន្ធុសម័យទំនើបនៅ Mindanao ដោយអំពាវនាវឲ្យមានការយកចិត្តទុកដាក់ដល់ការណ៍ដែលថា តំបន់នេះរួមមាន "ប្រជាជនត្រីភាគី" គឺ អំបូរម៉ូរ៉ូ អំបូរ Lumad និងអ្នកតាំងទីលំនៅជាគ្រីស្ទសាសនិក។

ពួកមូស្លីម ឬដែលពួកគេហៅខ្លួនថា ម៉ូរ៉ូ ឬ Bangasamoro ("ប្រជាជាតិម៉ូរ៉ូ") មានភាសាជាតិពន្ធ ១៣ ក្រុម រួមមាន Iranun, Jama Mapun, Palawani, Molbog, Kalagan, Kalibugan, Maguindanao, Maranao, Sama, Sangil, Tausug, Badjao, និង Yakan[4]។ សព្វថ្ងៃនេះ Rodil ប៉ាន់ស្មានថា ពួកគេមានចំនួនប្រមាណ ២០ ភាគរយនៃប្រជាជនសរុបនៅ Mindanao និង Sulu។

Lumad ជាពាក្យប្រើសម្រាប់ក្រុមកុលសម្ព័ន្ធមិនមែនមូស្លីម និងមិនមែនគ្រីស្ទសាសនិក ឬ "សហគមន៍វប្បធម៌" នៅ Mindanao ក៏មានភាពចម្រុះពូជសាសន៍ផងដែរ។ ពួកគេមានក្រុមភាសាជាតិពន្ធដែលមិនមែនមូស្លីម រួមមាន Ata, Bagobo, Mamanua, Mandaya, Kamayo, Mangguwangan, Manobo, Mansaka, Matigsalog, Subanun, Tagakaolo, Tala-andig, T'boli, Tiruray និង Ubo។ ក្រុមទាំងនេះភាគច្រើនកាន់សាសនាគ្រីស្ទ ឬកាន់សាសនាគ្រីស្ទមួយផ្នែក និងខ្លះទៀតកាន់សាសនាអ៊ីស្លាមមួយផ្នែក។ ជាងនេះទៀត មានការត្រួតគ្នាខ្លះ ដូចជាពួក Maranao ដែលកាន់សាសនាគ្រីស្ទនៅតំបន់ភ្នំ។ បើតាមជំរឿនឆ្នាំ១៩៩០ ក្រុមជាតិពន្ធទាំងនេះមានចំនួនប្រមាណ ៥ ភាគរយក្នុងចំណោមប្រជាជនសរុបនៅ Mindanao។

ក៏ប៉ុន្តែ ពួកគ្រីស្ទសាសនិកក៏ជាក្រុមជនជាតិដើមភាគតិចនៅ Mindanao ដែរ ដោយសារប្រជាជននិយាយភាសា Visayan ជិត ២០០.០០០ នាក់នៅ Mindanao ខាងជើង និងខាងកើត ត្រូវបានបញ្ចូលទៅក្នុងសាសនិកគ្រីស្ទក្នុងសម័យអាណានិគមអេស្ប៉ាញ។ ក្នុងចំណោមនោះ ពួកគេរួមមានប្រជាជនមួយចំនួននៅ Butuan, Davao, កោះ Camiguin, Cagayan de Oro, Misamis Oriental, Iligan, Ozamiz, Dapitan, Dipolog, និងអំបូរ Chavacano នៅក្រុង Zamboanga។ នាពេលបច្ចុប្បន្ន ប្រជាជនទាំងនេះត្រូវបានធ្វើសមាហរណកម្មទៅក្នុងប្រជាជនជាគ្រីស្ទសាសនិកទូទៅនៅ Mindanao តែនៅមានគ្រាមភាសាខុសៗគ្នា ជាពិសេសក្នុងចំណោមអំបូរ Chavacanos។ ពីមុនមក ពួក Chavacanos គឺជាជនជាតិដើមនៅ Ternate នៅលើប្រជុំកោះ Moluccan ភាគខាងកើតប្រទេសឥណ្ឌូនេស៊ី ហើយជាគ្រីស្ទសាសនិក។ ពួកគេត្រូវបាននាំយកធ្វើទាហានទៅ Zamboanga និងម៉ានីល នៅពាក់កណ្តាល (ឬដើម) ទសវត្សរ៍១៨០០។

---

[4] សូមមើល "Re-establishing Order in the Community and its Connection with Biodiversity Conservation" និពន្ធដោយ Rudy B. Rodil។ ឯកសារត្រៀមធ្វើបទបង្ហាញនៅឯសិក្ខាសាលាស្តីពីការកែប្រែជម្លោះ និងការអភិរក្សជីវចម្រុះ នៅក្រុង Cagayan de Oro City ថ្ងៃទី១១-១៣។ បណ្ឌិត Rodil បានលើកជាទឡ្ហីករណ៍ថា ក្រុមមូស្លីម/ម៉ូរ៉ូនៅ Mindanao សរុបមាន ១១ ក្រុម តែគាត់មិនបានបញ្ចូលក្រុមជាច្រើនទៀត ដូចជាពួកពនេចរតាមទូកនៅសមុទ្រគឺអំបូរ Badjao ដែលយើងបានបន្ថែមនៅទីនេះ (សូមមើល៖ http://www.mindanews.com/peprcs/peacetalk/rodil.shtml)។

ពួកអ្នកតាំងទីលំនៅ ដែលជាបុព្វបុរសម្ចាស់ស្រុកគ្រីស្ទសាសនិកភាគច្រើននៅ Mindanao បច្ចុប្បន្ន មានចំនួន ៧០ ភាគរយក្នុងចំណោមប្រជាជនហ្វីលីពីនកាន់សាសនាគ្រីស្ទនៅ Mindanao។ ដោយសារគេមិនអាចបែងចែកឲ្យបានដាច់ស្រឡះនូវអ្នកដែលបានធ្វើចំណាកស្រុក និងអ្នកដែលបានរស់នៅយូរអង្វែងនៅ Mindanao នោះ តួលេខ ៧០ ភាគរយនេះ គឺជាការគិតបញ្ចូលរួមគ្នាតែម្តង។

ក្នុងអំឡុងពេលគ្រប់គ្រងដោយអាណានិគមអាមេរិក ជនជាតិហ្វីលីពីនម៉ូរ៉ូ និង Lumad ត្រូវបានបែងចែក និងគ្រប់គ្រងដាច់ដោយឡែកពីគ្នា ជាកុលសម្ព័ន្ធម៉ូរ៉ូ និងកុលសម្ព័ន្ធព្រៃ ខុសពីប្រជាជនភាគច្រើនកាន់សាសនាគ្រីស្ទ "ដែលមានវប្បធម៌ខ្ពង់ខ្ពស់"។ នៅឆ្នាំ១៩៥៧ រដ្ឋាភិបាលហ្វីលីពីនបានប្រកាសជាផ្លូវការថា ប្រជាជនហ្វីលីពីនពុំមែនគ្រីស្ទសាសនិក នឹងត្រូវហៅថាប្រជាជនវប្បធម៌ភាគតិចជាតិ។ ដូចបណ្ឌិត Rodil ធ្វើការកត់សម្គាល់គឺថា ក្រោយមក រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៣ បានកំណត់ឈ្មោះហៅពួកគេថាជា "សហគមន៍វប្បធម៌" ហើយបន្ទាប់មករដ្ឋធម្មនុញ្ញឆ្នាំ១៩៨៧ បានហៅពួកគេថា "សហគមន៍វប្បធម៌ជនជាតិដើមភាគតិច"។ ការណ៍ដែលថាប្រជាជនទាំងអស់នេះជាជនជាតិដើមភាគតិច នៅតែជាប់ស្នាមជាប្រភេទភាសាជាតិពន្ធុនេះជារៀងរហូតមក។

នៅខែសីហា ឆ្នាំ២០០៤ បណ្ឌិត Moctar Matuan ជាអគ្គនាយកវិទ្យាស្ថានសន្តិភាព និងអភិវឌ្ឍន៍នៅ Mindanao នៅសាកលវិទ្យាល័យរដ្ឋ Mindanao ក្រុង Marawi City បានធ្វើការសង្ខេបអំពីប្រវត្តិនៃការខិតខំប្រឹងប្រែងចរចាស្វែងរកសន្តិភាពនៅ Mindanao មូស្លីម[5]។ គាត់បានធ្វើការកត់សម្គាល់ថា នៅឆ្នាំ១៩៧៥ មានតែមជ្ឈមណ្ឌលស្រាវជ្រាវ Dansalan មួយគត់ ដែលបានព្យាយាមលើកឡើងនូវរូបភាពអវិជ្ជមានដែលថា ជនជាតិហ្វីលីពីនម៉ូរ៉ូ និងគ្រីស្ទសាសនិកនៅ Mindanao បានបង្កើតកិច្ចសន្ទនារវាងគ្នា និងគ្នា។ មកដល់ពេលនោះ ជម្លោះហិង្សាបានកើតឡើងនៅ Mindanao រួចហើយ។ នៅទសវត្សរ៍១៩៨០ មានពីរបីក្រុមទៀតបានចូលរួមក្នុងកិច្ចសន្ទនានោះដែរ គឺ មជ្ឈមណ្ឌលសិក្សាអំពីសន្តិភាពនៅហ្វីលីពីនភាគខាងត្បូង នៅសាកលវិទ្យាល័យរដ្ឋ Mindanao នៅក្រុង Marawi និងមជ្ឈមណ្ឌលសន្តិភាពនៅសាកលវិទ្យាល័យ Notre Dame។ បញ្ហានានាដែលមជ្ឈមណ្ឌលទាំងនេះបានលើកឡើង គឺផ្តោតទៅលើសមភាពនៃសិទ្ធិ ភាពចាំបាច់នៃការថែរក្សាសន្តិភាព និងកំណើនសេដ្ឋកិច្ច និងអភិវឌ្ឍន៍។ លោកបណ្ឌិតយល់ឃើញថា ប្រធានាធិបតី Fidel Ramos ជាប្រធានាធិបតីដំបូងគេដែលមានចំណាប់អារម្មណ៍ក្នុងការស្វែងរកសន្តិភាពនៅ Mindanao។

ក្នុងការពិភាក្សាអំពីបញ្ហាជាច្រើនដែលបង្កើតជា "បញ្ហានៅ Mindanao" បណ្ឌិត Matuan បានលើកឡើងដូចខាងក្រោម៖

[5] ការបង្រៀននៅឯសកម្មភាពតាមដាន សម្រាប់គម្រោង ACCESS Philippines នៅ Cagayan de Oro ខែសីហា ឆ្នាំ២០០៤។

- ភាពក្រីក្រ វិសមភាព និងការបំផ្លាញបរិស្ថាន។
- អំពើពុករលួយផ្នែកនយោបាយ។
- រូបភាពអវិជ្ជមានដែលបង្កឡើងដោយប្រជាជនកាន់សាសនាគ្រឹស្ទ ម៉ូរ៉ូ និង Lumad រវាងគ្នានឹងគ្នា។
  - ការខកខានរបស់រដ្ឋាភិបាលថ្នាក់ជាតិ ក្នុងការធ្វើសមាហរណកម្មប្រជាជនម៉ូរ៉ូទៅក្នុងអត្តសញ្ញាណជាតិហ្វីលីពីន។
  - ការទទួលផលផ្នែកសេដ្ឋកិច្ចពីធនធាននៅ Mindanao និងការធ្វើចំណាកស្រុករបស់ប្រជាជនហ្វីលីពីនពីភាគខាងជើង នាំឲ្យបាត់បង់ទឹកដីដូនតា។
  - ការតស៊ូរបស់ប្រជាជនម៉ូរ៉ូ ដើម្បីទទួលការស្វ័យគ្រប់គ្រង។

ដូចដែលគាត់បានធ្វើការកត់សម្គាល់ កត្តាទាំងអស់នាំឲ្យប្រជាជនហ្វីលីពីនម៉ូរ៉ូ និង Lumad បច្ចុប្បន្នបាត់បង់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច នយោបាយ យ៉ាងធំធេង ពុំមានការទទួលស្គាល់នៅថ្នាក់ជាតិ និងការគោរពដល់អត្តសញ្ញាណវប្បធម៌ និងសាសនាដោយឡែករបស់ពួកគេ និងការយល់ថាពុំមានសន្តិសុខ ភាពអស់សង្ឃឹម និងការស្អប់ខ្ពើមចំពោះរដ្ឋាភិបាលថ្នាក់ជាតិ។ ក្រៅពីមិនមានឱកាសក្នុងការសម្តែងការព្រួយបារម្ភ និងទទួលបានជំនួយពីរដ្ឋាភិបាល ប្រជាជនហ្វីលីពីនម៉ូរ៉ូ និង អំបូរ Lumad ជួបប្រទះភាពក្រីក្រយ៉ាងធ្ងន់ធ្ងរ អយុត្តិធម៌សង្គម និងរងការកេងប្រវ័ញ្ចពីមេដឹកនាំ និងមេបញ្ជាការកងទ័ពដែលពុករលួយដូចគ្នា។ ពួកគេយល់ឃើញថា រដ្ឋាភិបាលជាតិហ្វីលីពីនព្រងើយកន្តើយចំពោះស្ថានភាពរបស់ពួកគេ ហេតុដូច្នេះពួកគេមិនមានអារម្មណ៍ថាមានភាពជាម្ចាស់ ឬភក្តីភាពជារដ្ឋនៅហ្វីលីពីនទេ។

ការបាត់បង់ទឹកដីកដូនតាទៅលើដៃប្រជាជនជាអ្នកចំណូលថ្មី និងការផ្លាស់ទីកន្លែងយ៉ាងឆាប់រហ័សពីបណ្តារដ្ឋអ៊ីស្លាម និងមេកន្ទ្រាញ ចំពោះមនុស្សភាគតិចផ្នែកវប្បធម៌ និងសាសនាដែលបាត់បង់អត្ថប្រយោជន៍ នៅតែជាចំណុចស្នូលនៃជម្លោះនៅ Mindanao។ ប្រជាជនអ៊ីស្លាមសរុបនៅ Mindanao មានចំនួនប្រហែល ៣៩,២៩ ភាគរយនៅឆ្នាំ១៩០៣ តែនៅត្រឹម ២០,១៧ ភាគរយនៅឆ្នាំ១៩៧៥។ ប្រជាជន Lumad សរុបមានចំនួនប្រហែល ២២,១១ ភាគរយនៅឆ្នាំ១៩០៣ និងនៅសល់ត្រឹមតែ ៦,៨៦ ភាគរយប៉ុណ្ណោះនៅឆ្នាំ១៩៧៥[6]។

ការកេងប្រវ័ញ្ចទៅលើបរិស្ថានដ៏សំបូរបែបនៅ Mindanao ត្រូវបានចាប់ផ្តើមជាដំបូងដោយសារផលប្រយោជន៍អាមេរិក បន្ទាប់មកដោយប្រជាជនហ្វីលីពីនគ្រឹស្ទសាសនិកដែលបានធ្វើទំនើបកម្ម និងពួកមូលធននិយមក្នុងវិស័យជំនួញ ហើយក៏ដោយសារក្រុមហ៊ុនសាជីវកម្មពហុជាតិផងដែរ។ សម្បទានអាជីវកម្មកាប់ឈើ

---

[6] Rodil, op cit, ទំព័រ ៧។

ការកែប្រែដីវាលស្មៅ ការធ្វើបណ្ណកម្មសិទ្ធិដីធ្លីតាមផ្លូវច្បាប់ដ៏ស្មុគស្មាញដែលប្រជាជនហ្វីលីពីនម៉ូរ៉ូ និង Lumad ពុំសូវមានការយល់ដឹង ហើយបច្ចុប្បន្ននេះសម្បទានអាជីវកម្មរ៉ែ បណ្តាលឲ្យបាត់បង់ទឹកដីកំណើត និងធនធានរបស់ខ្លួនយ៉ាងធំធេងដែលជាមូលដ្ឋានដើម្បីអភិវឌ្ឍសហគមន៍របស់ខ្លួន។ ក្រុមហ៊ុនពហុជាតិបានបើកផ្លូវទៅការបង្កើតជាដីចម្ការធំៗ និងភាពជាដៃគូររបស់ជាជនហ្វីលីពីនជាគ្រីស្ទសាសនិក ដើម្បីអភិវឌ្ឍធនធាននៅ Mindanao ដោយយកចិត្តទុកដាក់តិចតួចដល់បញ្ហានៃការរស់នៅរបស់ប្រជាជនម៉ូរ៉ូ និង Lumad និងការស្អប់ខ្ពើមកាន់តែកើនឡើងក្នុងចំណោមប្រជាជនជាម្ចាស់ស្រុក។ នៅក្នុងប្រវត្តិសង្ខេបនេះ ជម្លោះដែលមានលក្ខណៈជាត្រីភាគីបានលេចចេញជារូបរាងឡើង។ វាមិនមែនគ្រាន់តែជាជម្លោះរវាងសាសនាគ្រីស្ទ និងពួកមូស្លីមប៉ុណ្ណោះទេ ហើយក៏មិនមែនត្រឹមតែជាជម្លោះរវាងជនជាតិដើមភាគតិចជាម្ចាស់ស្រុកនៅ Mindanao និងអ្នកតាំងទីលំនៅចំណាកស្រុកដែរ។ ការធ្វើនយោបាយភាវូបនីយកម្មចំពោះប្រជាជនជាជនជាតិដើមភាគតិចជាបីប្រភេទ (ម៉ូរ៉ូ គ្រីស្ទសាសនិក និង Lumad) កើតឡើងជាបន្ត ពីព្រឹត្តិការណ៍នាពេលថ្មីៗក្នុងសតវត្សរ៍ទី២០។ មុនពេលនោះ ក្រុមទាំងនេះមានការប្រាស្រ័យទាក់ទងគ្នា ចងសម្ព័ន្ធភាព ធ្វើជំនួញ រៀបការជាមួយគ្នា ហើយជួនកាលចាត់ទុកក្រុមនីមួយៗជាទាសករ តែមិនទាន់ក្លាយជាក្រុមប្រឆាំង (ទោះបីចម្រុះ) នឹងគ្នាទេ។ វាជាដំណើរការដែលធ្វើឲ្យបាត់បង់អត្ថប្រយោជន៍ មិនត្រឹមតែដោយសារចំនួនដ៏ច្រើនលើសលប់នៃអ្នកតាំងទីលំនៅជាគ្រីស្ទសាសនិកប៉ុណ្ណោះទេ តែដោយសារការបាត់បង់ទឹកដីកំណើត និងការភ័យខ្លាចនឹងការបាត់បង់អត្តសញ្ញាណវប្បធម៌ និងសាសនារបស់ខ្លួនថែមទៀត ដែលក្លាយជាមូលដ្ឋាននៃជម្លោះ។

នៅក្នុងអត្ថបទថ្មីមួយ Archbishop Orlando B. Quevedo ធ្វើការកត់សម្គាល់ថា ការវិភាគរបស់រដ្ឋាភិបាលហ្វីលីពីនអំពីការបះបោរនៅ Mindanao បង្ហាញពីឫសគល់ចម្បងចំនួន ៤ នៃជម្លោះ[7]៖

១. ភាពក្រីក្រ រួមទាំងផលិតភាពទាប ការកំណត់ជាបទល្មើស ការធ្វើឲ្យបាត់បង់អត្ថប្រយោជន៍ និងការបំផ្លាញបរិស្ថាន។
២. គ្រោះអវិជ្ជា រួមទាំង សាលារៀនខ្សត់ខ្សោយ និងការអប់រំ។
៣. ជំងឺដង្កាត់ រួមទាំង កង្វះអាហារូបត្ថម្ភ និងការពុំទទួលបានសេវាថែទាំសុខភាពសមរម្យ។
៤. ភាពអយុត្តិធម៌ រួមទាំងការរំលោភសិទ្ធិមនុស្ស ជម្លោះដីធ្លី និងអំពើពុករលួយ។

---

[7] Quevedo, Orlando B., "Injustice: the Root of Conflict in Mindanao" ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ (សូមមើល៖ http://www.mindanews.com/peprcs/peacetalk/quevedo.shtml)។

ចំណុចដែលគួរឲ្យភ្ញាក់ផ្អើលអំពីការពិនិត្យទៅលើឫសគល់ជម្លោះគឺថា ពុំមានការលើកឡើងនូវកង្វះនៃការយកចិត្តទុកដាក់ពីថ្នាក់ជាតិ ក្នុងការពង្រឹងនិងថែរក្សាអត្តសញ្ញាណវប្បធម៌ ជាតិពន្ធុ និងសាសនារបស់ប្រជាជនហ្វីលីពីនម៉ូរ៉ូ និងមិនមែនមូស្លីម អំបូរ Lumad មិនមែនជាគ្រឹស្ទសាសនិកនៅ Mindanao។ ប៉ុន្តែ មានតែតាមរយៈការបង្កើតនូវការយល់ដឹង និងការគោរពដល់ភាពចម្រុះនៃជាតិពន្ធុ និងសាសនាក្នុងចំណោមប្រជាជនទាំងអស់នៅហ្វីលីពីនទេ ទើបអាចបង្កើតបាននូវបរិយាកាសនៃការអត់ឱន និងយុត្តិធម៌នៅភាគខាងត្បូង។ គម្រោង ACCESS Philippines ត្រូវបានបង្កើតឡើង ដើម្បីសម្រេចទៅតាមគោលដៅនោះ ជាពិសេសគឺការនាំយកយុវជនដែលមានប្រវត្តិមកពីជាតិពន្ធុ និងសាសនាខុសៗគ្នានៅក្នុងតំបន់ស្វយ័ត Mindanao មូស្លីម និងបរិវេណជុំវិញ ឲ្យធ្វើការរួមគ្នា ដើម្បីស្វែងរកសន្តិភាព និងស្ថាបនាស្ពានមួយឆ្ពោះទៅកាន់អនាគតថ្មី។

<u>ស្ថានភាពបច្ចុប្បន្ននៃកិច្ចខិតខំប្រឹងប្រែងស្វែងរកសន្តិភាពនៅ Mindanao</u>

កិច្ចខិតខំប្រឹងប្រែងស្វែងរកសន្តិភាពនៅ Mindanao មកពីគ្រប់ទិសទី។ កិច្ចខិតខំប្រឹងប្រែងទាំងនោះកើតឡើងនៅកម្រិតបុគ្គល មូលដ្ឋាន តំបន់ ការិយាល័យធិបតេយ្យ រដ្ឋ និងអន្តរជាតិ។ មានគំនិតផ្តួចផ្តើមនៅហ្វីលីពីន និងការគាំពារពីបរទេស ព្រមទាំងមានសកម្មភាពពីរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល។ ជាការសំខាន់ណាស់ដែលថា តំណាងរដ្ឋាភិបាល និងពួកឧទ្ទាមមានឆន្ទៈក្នុងការពិភាក្សាពីភាពខុសគ្នា និងសម្រេចបានដំណោះស្រាយនៃជម្លោះ។ តួអង្គនានាដូចជា រដ្ឋហ្វីលីពីន សង្គមស៊ីវិល ប្រជាពលរដ្ឋទូទៅ អ្នកសង្កេតការណ៍បរទេស រដ្ឋបរទេស ស្ថានទូត អង្គការនានាដូចជាសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (អាស៊ាន) សហភាពអឺរ៉ុប (EU) ព្រមទាំងសហរដ្ឋអាមេរិក និងអូស្ត្រាលីបានបង្ហាញនូវចំណាប់អារម្មណ៍យ៉ាងធំធេង ក្នុងការដោះស្រាយបញ្ហានានានៅ Mindanao។ តួអង្គទាំងអស់យល់ស្រប និងយល់ឃើញថា សន្តិភាពអាចទទួលបាន ប្រសិនបើមានយុត្តិធម៌សង្គម និងសេដ្ឋកិច្ច។ ភាពក្រីក្រ និងអំពើឧទ្ទាមកម្មមានទំនាក់ទំនងរវាងគ្នានិងគ្នាយ៉ាងជិតស្និទ្ធ។

សកម្មភាពតាមដានរបស់កម្មវិធី ACCESS Philippine បញ្ជាក់ថា ប្រជាពលរដ្ឋទូទៅ សិស្សនិស្សិត យុវជន អ្នករៀបចំសហគមន៍ និងសមាសធាតុផ្សេងៗទៀតនៃសង្គមស៊ីវិល មានតួនាទីរឹងមាំ និងចម្បងក្នុងការចូលរួមចំណែកដោះស្រាយជម្លោះបន្តិចម្តងៗនៅ Mindanao។ ក្រៅពីត្រឹមតែគិតដល់គោលដៅធំៗ បុគ្គលម្នាក់ៗដែលមានជំនឿលើសាសនាគ្រឹស្ទ អ៊ីស្លាម និងប្រព័ន្ធជំនឿជនជាតិដើមភាគតិចផ្សេងទៀត អាចស្ថាបនាសន្តិភាពបានមួយជំហានម្តងៗ ដោយចាប់ផ្តើមពីខ្លួនឯង និងផ្សព្វផ្សាយនូវសុឆន្ទៈនេះទៅកាន់ក្រុមគ្រួសារ មិត្តភក្តិ សហគមន៍ សាលារៀន ទីកន្លែងគោរពបូជា និងសង្គមទាំងមូលបាន។

ក្នុងអំឡុងខែប្រារព្ធពិធីបុណ្យតមអាហារអ៊ីស្លាម ឬ Ramadan នៅឆ្នាំ២០០៤ មានបណ្ដាប្រទេសជាច្រើនចាប់ផ្ដើមចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងស្វែងរកសន្តិភាពនៅ Mindanao។ អង្គការសន្និសីទអ៊ីស្លាម (OIC) គាំទ្រដល់ដំណើការស្វែងរកសន្តិភាពនៅ Mindanao ដែលប្រទេសម៉ាឡេស៊ីបានដើរតួនាទីយ៉ាងធំធេង។ នាពេលថ្មីៗនេះ នៅពេលចូលរួមកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) ពីថ្ងៃទី០៧ ដល់ទី០៩ ខែតុលា ឆ្នាំ២០០៤ នៅទីក្រុងហាណូយ ប្រទេសវៀតណាម លោកស្រីប្រធានាធិបតី Gloria Macapagal Arroyo បានថ្លែងអំណរគុណដល់បណ្ដាមេដឹកនាំអាស៊ីអគ្នេយ៍ និងអឺរ៉ុប ចំពោះការគាំទ្រដល់ដំណើរការសន្តិភាពជាមួយពួក MILF (កាសែត Mindanao Times ចុះផ្សាយថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤)។ ពួក MILF បានទទួលការគាំទ្រពីប្រជាជននៅតាមទីជនបទ នៅពេលដែលភាពក្រីក្រ និងការមិនអភិវឌ្ឍន៍បានលើកកម្ពើងដល់អំពើឧទ្ទាមកម្ម (BBC, 2004)។

អ្នកចរចាពីភាគីរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន (GRP) និងពួករណសិរ្សអ៊ីស្លាមម៉ូរ៉ូ (MILF) ដែលមានកម្លាំង ១២.០០០ នាក់ បានព្រមព្រៀងគ្នាបង្កើតឲ្យមានក្រុមតាមដានអន្តរជាតិ (IMT) នៅពេលប្រទេសម៉ាឡេស៊ីរៀបចំកិច្ចប្រជុំពីថ្ងៃទី១៩ ដល់ទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ នៅទីក្រុងគុឡាឡាំពួរ។ កិច្ចពិភាក្សារវាង GRP និងពួក MILF បានចាប់ផ្ដើមនៅខែមករា ឆ្នាំ១៩៩៧ ក្រោយពេល GRP ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពចុងក្រោយជាមួយរណសិរ្សរំដោះជាតិម៉ូរ៉ូ (MNLF)។ ក៏ប៉ុន្តែ ក្រោយពេលចាប់ផ្ដើមកិច្ចពិភាក្សា អតីតប្រធានាធិបតី Joseph Estrada បានចេញបញ្ជាឲ្យធ្វើការវាយប្រយុទ្ធដោយគ្មានការលើកលែងទៅលើទីបញ្ជាការ MILF នៅជំរុំ Abubakar ក្នុងក្រុង Matanog នៅ Maguindanao ហើយលោកស្រីប្រធានាធិបតី Arroyo បានចេញបញ្ជាទៅកងទ័ពហ្វីលីពីនឲ្យវាយប្រហារទៅអ្វីដែលគេហៅថាជម្រករបស់ MILF នៅក្រុង Pikit នៅ Cotabato ភាគខាងជើង។ ឥរិយាបថរក្សាភាពស្ងៀមស្ងាត់បានទទួលជោគជ័យតាំងពីពេលនោះមកនៅក្នុងរដ្ឋាភិបាលលោកស្រី Arroyo ប៉ុន្តែអំពើប្រទូស្តរាយ និងការអះអាងថា ក្រុមឧទ្ទាមមួយចំនួននៅក្នុង MILF បានផ្ដល់ជាជម្រកដល់សមាជិកបណ្ដាញឧទ្ទាម Jemaah Islamiyah បានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការស្វែងរកសន្តិភាព និងបង្កជាការព្រួយបារម្ភក្នុងចំណោមភាគីទាំងអស់ ចំពោះការបន្តដំណើរការចរចាស្វែងរកសន្តិភាពតទៅទៀត។

បណ្ដាបញ្ញវ័ន្តជាច្រើនបានសម្ដែងនូវការខកចិត្តផង និងក្ដីសង្ឃឹមផងថានឹងមានដំណោះស្រាយជម្លោះនៅ Mindanao។ លោក Abhoud Syed M. Lingga (ឆ្នាំ២០០៤) ជាអគ្គនាយកវិទ្យាស្ថានសិក្សាស្រាវជ្រាវ Bangsamoro បានលើកជាទឡ្ហីករណ៍ថា ការចរចាស្វែងរកសន្តិភាពរវាង GRP និងពួកe MILF នឹងមិនទាន់គ្រប់គ្រាន់ដើម្បីបង្កើតបានសន្តិភាពប្រកបដោយចីរភាពបានឡើយ។ គាត់ថ្លែងថា ចាំបាច់ត្រូវមានរូបមន្តថ្មីមួយដែលធានាឲ្យមានការចូលរួមពីប្រជាជននៅ Bangsamoro ផ្ទាល់ ក្នុងការសម្រេចពីទិសដៅនៃទំនាក់ទំនង

នយោបាយរបស់ខ្លួននាពេលអនាគត ជាមួយរដ្ឋាភិបាលថ្នាក់ជាតិ។ គាត់ស្នើសុំឲ្យមានការធ្វើប្រជាមតិមួយដែលផ្តល់ឲ្យប្រជាជននៅ Bangsamoro នូវជម្រើសអំពីឋានៈនយោបាយមួយរវាងស្វ័យភាពទូលំទូលាយ ទំនាក់ទំនងបែបសហព័ន្ធ ឬឯករាជភាព។ បន្ទាប់មក គាត់ធ្វើការកត់សម្គាល់ពីភាពចាំបាច់នូវការដាក់ពង្រាយកងកម្លាំងរក្សាសន្តិភាពរបស់ភាគីទីបី ដើម្បីបញ្ចៀសនូវអំពើប្រទូស្តរាយថែមទៀត។

លោកស្រី Morgan (ឆ្នាំ២០០៣) លើកឡើងនូវការប្រុងប្រយ័ត្នមួយចំនួនអំពីថាតើការធ្វើប្រជាមតិនេះអាចជួយអ្វីខ្លះក្នុងការដោះស្រាយជម្លោះ ដោយពិចារណាដល់វិសាលភាពនៃដៃគូរពាក់ព័ន្ធ បញ្ហានានា និងតួអង្គដែលពាក់ព័ន្ធក្នុងជម្លោះ។ នាពេលនេះ Mindanao គឺជាលំនៅដ្ឋានរបស់ប្រជាជនជាគ្រឹស្ទសាសនិកភាគច្រើនទោះបីអំបូរ Lumad នៅតែទាមទារថា ដែនកោះនេះទាំងមូលជាទឹកដីដូនតារបស់ខ្លួនក៏ដោយ។ លោកស្រីលើកជាទឡ្ហីករណ៍ថា ក្រុមនីមួយៗនៅ Mindanao នឹងមានតួនាទីជាក់លាក់នៅក្នុងដំណើការធ្វើប្រជាមតិ ដើម្បីធានាឲ្យមានតំណាងដោយយុត្តិធម៌ និងការគាំទ្រដល់លទ្ធផលនៃការធ្វើប្រជាមតិនោះ។ លោកស្រីយល់ឃើញថា សង្គមស៊ីវិលគឺជាទីកន្លែងដែលគួរចាប់ផ្តើមកិច្ចសន្ទនារបៀបនេះ មិនមែនជាការធ្វើប្រជាមតិទេ ហើយពួកគ្រឹស្ទសាសនិក ពួកម៉ូរ៉ូ និងពួក Lumad ចាំបាច់ត្រូវធ្វើការចរចាគ្នា និងសម្រេចថា ដំណោះស្រាយដែលល្អបំផុតក្នុងការដោះស្រាយជម្លោះ គឺដំណោះស្រាយដែលមានការពឹងផ្អែករវាងគ្នានិងគ្នា ពុំមែនជាដំណោះស្រាយទាមទារឯករាជ្យនោះទេ។

តើការយល់ដឹងជាទូទៅអ្វីខ្លះដែលត្រូវយកមកធ្វើជាមូលដ្ឋានដើម្បីគាំទ្រដល់កិច្ចសន្ទនានេះ? បណ្ឌិត Nagasura Madale (ឆ្នាំ១៩៩៩) បានបញ្ចេញយោបល់ថា ការស្វែងរកមនោគមវិជ្ជាឯកភាពមួយទៅលើអត្តសញ្ញាណ អាចចាប់ផ្តើមដោយបង្ហាញនូវសញ្ញាណនៃភាពជាប្រជាជាតិមួយ ឬ bangsa/bansa។ ឧទាហរណ៍ ប្រជាជនអំបូរ Maranao (ប្រជាជនរស់នៅតាមដងទន្លេ) មានជំនឿថា ពួកគេជាតំណពូជពង្សពីបុព្វញាតិតែមួយ (salsila) និងហៅថាជាទស្សនៈ merepeda sa posed (ឧទាហរណ៍ បុគ្គលម្នាក់ៗគឺជាផ្នែកនៃទងផ្ចិតដ៏វែង)។ ជំនឿដែលថា ជនជាតិ Maranao គ្រប់រូបគឺជាតំណពូជពង្សតែមួយនេះ អាចកើតមកពីប្រភពពីរ៖ (១) វីរជននៅក្នុងទេវកថាឈ្មោះ Radia Indarapatra និង (២) ប្រភពពីអ៊ីស្លាម Sharief Kabungsuwan។ បើតាមនិទានកថាផ្ទាល់មាត់នេះ កូនចៅរបស់ពួកគេបានរៀបការជាមួយគ្នា និងបានទៅរស់នៅតំបន់ទន្លេ Lanao ហើយបានបញ្ចូលជនជាតិ Maranao ឲ្យកាន់សាសនាអ៊ីស្លាម។ អ៊ីស្លាមក៏បាននាំយកទស្សនៈទូលំទូលាយមួយនៃភាពជាបងប្អូនជាសាកល គឺទស្សនៈ ummah ឬថា សហគមន៍អ៊ីស្លាមដែលឆ្លងកាត់ព្រំដែនភូមិសាស្ត្រ ពូជសាសន៍ និងអត្តសញ្ញាណជាតិពន្ធុ។ បើតាមទស្សនៈនេះ មូស្លីមទាំងអស់គឺជាបងប្អូននឹងគ្នា ហើយអាចក្លាយជារាងកាយតែមួយ ប្រសិនបើផ្នែកណាមួយនៃ “រាងកាយ” រងការឈឺចាប់ រាងកាយទាំងមូលក៏រងការឈឺចាប់ដែរ។

ផ្ទុយទៅវិញ ប្រជាជនហ្វីលីពីនជាគ្រីស្ទសាសនិកបានភ្ជាប់ខ្លួនទៅនឹងទស្សនៈគ្រីស្ទសាសនាឆ្លងដែនពោលគឺ នំបុ័ងមួយដុំ រាងកាយមួយ ព្រលឹងមួយ។ ទស្សនៈទាំងនេះស្របទៅនឹងទស្សនៈសហគមន៍ ដូចនៅក្នុងទស្សនៈគ្រីស្ទសាសនា bajo de campana "នៅក្រោមជួង" និងទស្សនៈ bajo de masjid របស់អ៊ីស្លាមដែលថា "នៅក្រោមវិហារអ៊ីស្លាម"។ ទោះបីប្រការនេះធ្វើឲ្យជំនឿរបស់អំបូរ Lumad ចម្រុះត្រូវស្ថិតនៅកណ្តាលក៏ដោយ តែពួកគេក៏មានទស្សនៈថាស្ថិតនៅក្នុងសហគមន៍មួយដែលប្រសព្វទៅនឹងទស្សនៈរបស់ប្រជាជនហ្វីលីពីនអ៊ីស្លាម និងគ្រីស្ទសាសនិកដែរ។

ជាយូរមកហើយ ប្រព័ន្ធអប់រំនៅហ្វីលីពីនព្យាយាមដើរតួនាទីជាអ្នកបញ្ចូលទ្រឹស្តីនានា ឬថា វាជាស្ថាប័នឯកភាពមួយដែលបង្កើតឡើងដើម្បីបញ្ចូលក្រុមជនជាតិភាគតិចទៅជាបុគ្គលិកលក្ខណៈតែមួយ គឺជាជនជាតិហ្វីលីពីនកាន់គ្រីស្ទសាសនា។ ក៏ប៉ុន្តែជនជាតិហ្វីលីពីនម៉ូរ៉ូជាច្រើននៅតែប្រកាន់យកអត្តសញ្ញាណរបស់ខ្លួនជា ជនជាតិមូស្លីម និងស្ថិតនៅក្នុងសហគមន៍មូស្លីមធំ ទោះបីរដ្ឋាភិបាលថ្នាក់ជាតិខិតខំប្រឹងប្រែងបង្កើតជម្រើសនយោបាយផ្សេងក៏ដោយ។ ការបង្កើតតំបន់ស្វយ័ត Mindanao មូស្លីម គឺជាកាយវិការផ្នែកនយោបាយមួយរបស់រដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីបង្កើតឲ្យមានភាពស្រដៀងគ្នាទៅនឹងប្រព័ន្ធគ្រប់គ្រងដោយស្តេចស៊ុលតង់ ដែលនៅតែមានចែងក្នុងរដ្ឋធម្មនុញ្ញហ្វីលីពីន និងអធិបតេយ្យភាពរបស់ប្រទេសដដែល។ ទោះបីមិនបានល្អឥតខ្ចោះក្តី តែការបង្កើតតំបន់នេះ គឺដើម្បីផ្តល់ជម្រើសផ្នែកនយោបាយ ដោយមិនលះបង់អំណាចទាំងស្រុង។

តើតំបន់ស្វយ័ត ARMM បំពេញទៅតាមគោលបំណងនៃការស្ថាបនាខ្លឹមសារថ្មីនៃលទ្ធិជាតិនិយម និងអត្តសញ្ញាណជាតិក្នុងចំណោមជនជាតិ Bangsamoro បានដែរឬទេ? មានវិធីសាស្ត្រជាច្រើនក្នុងការសម្លឹងមើលបញ្ហានេះ។ ម្យ៉ាង មានស្ថាប័ន និងទស្សនៈបែបអ៊ីស្លាម ជាពិសេសក្នុងវិស័យអប់រំដែលត្រូវបានផ្តួចផ្តើមផ្តល់ជម្រើសដល់បំណងប្រាថ្នារបស់ជនជាតិម៉ូរ៉ូ ក្នុងការ "ធ្វើសមាហរណកម្មជាតិ" ទៅក្នុងទិដ្ឋភាពនយោបាយនៅថ្នាក់ជាតិ ដោយមិនឲ្យបាត់បង់អត្តសញ្ញាណជាតិពន្ធុ និងសាសនារបស់ខ្លួនជាជនជាតិមូស្លីម។ មនោគមវិជ្ជា និងក្របខណ្ឌនៃតំបន់ស្វយ័ត ARMM ដោយមិនទទួលយកទស្សនៈពួកបស្ចិមដែរថា "ការបែងចែករវាងព្រះវិហារគ្រីស្ទសាសនា និងរដ្ឋ" ហើយជនជាតិម៉ូរ៉ូជាច្រើនទទួលស្គាល់ថា វាជាវិធីសាស្ត្រមួយដើម្បីឲ្យរដ្ឋាភិបាលថ្នាក់ជាតិលើកឡើងនូវក្តីសុបិន្តរបស់ខ្លួនរាប់សតវត្សរ៍មកហើយ គឺស្វ័យភាពគ្រប់គ្រង។ ម្យ៉ាងវិញទៀត ក្របខណ្ឌ និងមនោគមវិជ្ជាសម្រាប់ការបង្កើតតំបន់ស្វយ័ត ARMM ជាប្រព័ន្ធ គឺផ្អែកទៅលើទស្សនៈប្រជាធិបតេយ្យប្រជាជនរបស់គ្រីស្ទសាសនិកភាគច្រើន និងទស្សនៈនៃការបែងចែករវាងវិហារគ្រីស្ទសាសនា និងរដ្ឋ។ ជនជាតិមូស្លីមជាច្រើនយល់ឃើញថា តំបន់ស្វយ័តនេះគួរផ្តោតទៅលើមនោគមវិជ្ជា din-un-Islam បែបអ៊ីស្លាម ជារបៀបនៃការរស់នៅ។ ទោះបី ស្ថាប័នមួយចំនួនរបស់រដ្ឋាភិបាលថ្នាក់ជាតិត្រូវបានបញ្ចូលទៅក្នុងតំបន់ស្វយ័ត

ARMM ក៏ដោយ តែមានទិដ្ឋភាពផ្សេងទៀតនៃការគ្រប់គ្រងបែបការិយាល័យធិបតេយ្យ មិនត្រូវបានបញ្ចូលទេ។ ហិរញ្ញវត្ថុ ពន្ធដារ សន្តិសុខជាតិ កិច្ចការបរទេស ការទទួលផលពីធនធានធម្មជាតិនៅក្នុងតំបន់នេះ និងការបែងចែកថវិកាជាតិប្រចាំឆ្នាំ នៅតែស្ថិតក្រោមការគ្រប់គ្រងយ៉ាងពេញលេញពីរដ្ឋាភិបាលថ្នាក់ជាតិនៅឡើយ។

ក្រុមការងារ IMT កំពុងពិនិត្យតាមដានការអនុវត្តកិច្ចព្រមព្រៀងឈប់បាញ់រវាង GRP-MILF។ តំណាងពីប្រទេសម៉ាឡេស៊ី ប្រ៊ុយណេ លីប៊ី អារ៉ាប៊ីសាអ៊ូឌីត បារ៉េន និងជប៉ុនមានសមាសភាពនៅក្នុងក្រុមការងារ IMT នេះ។

ក្រុមការងារ IMT នឹងបង្កើតការិយាល័យកណ្តាលរបស់ខ្លួននៅទីក្រុង Cotabato និងការិយាល័យសាខានៅក្រុង Zamboanga, Iligan, Davao និង General Santos។ ឯកអគ្គរដ្ឋទូតគុយបា ប្រេស៊ីល ឈីលី អាហ្សង់ទីន និងវេណេហ្ស៊ុយអេឡា ប្រចាំប្រទេសហ្វីលីពីនរួមគ្នាកោតសរសើរចំពោះខិតខំប្រឹងប្រែងរបស់ GRP និង MILF ក្នុងការស្វែងរកសន្តិភាពនៅហ្វីលីពីនភាគខាងត្បូង។ ប្រសិនបើមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពមួយដែលមានស្ថិរភាព និងប្រសិទ្ធភាពនោះ សហរដ្ឋអាមេរិក អូស្ត្រាលី និងបណ្តាប្រទេសមួយចំនួននៃសហភាពអឺរ៉ុបនឹងផ្តល់ជំនួយដល់ Mindanao។ តួអង្គទាំងអស់យល់ស្របគ្នាថា សេដ្ឋកិច្ច និងនយោបាយជាបញ្ហាមានសារសំខាន់ដូចគ្នា និងមានទំនាក់ទំនងដោយផ្ទាល់៖ បញ្ហាទាំងពីរនេះមានសារសំខាន់ចំពោះគ្នានិងគ្នាទៅវិញទៅមក។ ប្រសិនបើភាពក្រីក្រត្រូវបានលុបបំបាត់ ហើយជីវភាពរបស់ប្រជាជនមានភាពប្រសើរឡើងនោះ បទល្មើស និងបដិវត្តន៍នឹងអាចលុបបំបាត់បាន។ ដូចគ្នានេះដែរ ប្រសិនបើមានសណ្តាប់ធ្នាប់ និងស្ថិរភាពនោះ សេដ្ឋកិច្ចនឹងមានភាពរីកចម្រើន។ សព្វថ្ងៃនេះ ទំនាក់ទំនងផ្នែកនយោបាយរវាង MILF និងក្រុមបដិបក្ខរបស់ខ្លួនផ្សេងទៀត ដៃគូពាក់ព័ន្ធជាជនស៊ីវិល និងរដ្ឋាភិបាលថ្នាក់ជាតិនៅតែស្ថិតក្នុងសភាពស្មានៗ ការចរចា និងមតិយោបល់ចម្រុះគ្នា។

តើនៅទីបំផុត សន្តិភាពនៅតែពិបាកនឹងទទួលបានឬ? អ្នកមានគំនិតទុទ្ទិដ្ឋិនិយមអះអាងថា គ្មានក្តីរំពឹងថានឹងទទួលបានសន្តិភាពឡើយ។ ក៏ប៉ុន្តែបណ្តាអ្នកមានគំនិតសុទិដ្ឋិនិយមជំទាស់ថា សន្តិភាពកើតមានបន្តិចម្តងៗពីបុគ្គលម្នាក់ៗ និងសកម្មភាពមួយម្តងៗ។ គម្រោង ACCESS Philippines ត្រូវបានបង្កើតឡើងដើម្បីឧទ្ទិសដល់គោលដៅសន្តិភាពនេះ ពីបណ្តាអ្នកមានជំនឿចិត្ត និងក្រុមជាតិពិន្ទុទាំងអស់ នៅហ្វីលីពីនភាគខាងត្បូង ដែលមានមហិច្ឆតាក្នុងការទទួលឲ្យបានសន្តិភាពដែលមានស្ថិរភាពយូរអង្វែង។ ការគោរព ការផ្តល់តម្លៃ ការអត់ឱន និងការផ្សះផ្សាជាតិអាស្រ័យទៅលើការយល់ដឹងអំពីជម្លោះឲ្យបានទូលំទូលាយ និងប្រវត្តិសាស្ត្ររបស់ប្រជាជននៅ Mindanao ហើយគម្រោងនេះ បានបោះជំហានមួយជំហានឆ្ពោះទៅទិសដៅនោះ។

# ឯកសារយោង


Baylon, G. J. ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៤, កិច្ចព្រមព្រៀងសន្តិភាពនៅ Mindanao ជាសញ្ញាណល្អសម្រាប់ការធ្វើវិនិយោគពីអាមេរិក និងអាមេរិកឡាទីន, សារព័ត៌មាន Silangan Shimbun គេហទំព័រ៖ http://www.silanganshimbun.com/October2004_update/142004_4.htm។

BBC News UK Edition ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤, សេចក្តីផ្តើមនៃជម្លោះនៅហ្វីលីពីន, គេហទំព័រ៖ http://news.bbc.co.uk/1/hi/world/asia-pacific/1695576.stm។

Dalangin-Fernandez, L. ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៤, លោកស្រី Arroyo មានប្រសាសន៍ថា "សន្តិភាពស្ថិតក្នុងដៃ" នៅ Mindanao, INQ7.net, សារព័ត៌មាន Agence France-Press គេហទំព័រ៖ http://news.inq7.net/breaking/index.php?index=1&story_id=14991។

ក្រសួងការបរទេស ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៤, សន្តិភាពជាមួយពួក MILF នឹងលេចចេញជារូបរាងនាពេលដ៏ខ្លី នៅពេលក្រុមអ្នកតាមដានអន្តរជាតិមកដល់, សេចក្តីប្រកាសព័ត៌មាន គេហទំព័រ៖ http://www.dfa.gov.ph/news/pr/pr2004/oct/pr627.htm។

Elusfa, R. ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤, ពួក MILF មានក្តីសង្ឃឹមទៅលើក្រុមការងារ, កាសែត Mindanews គេហទំព័រ៖ http://www.mindanews.com/2004/10/20nws-milf.html។

Gevera, M. ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤, ក្រុមស្វែងរកសន្តិភាពពីប្រទេសម៉ាឡេស៊ីទៅដល់ Mindanao, សារព័ត៌មាន Philippine News Agency គេហទំព័រ៖ http://www.pia.gov.ph/press/p041013.htm។

Lingga, Abhoud Syed M. ឆ្នាំ២០០៤ "ដំណើរការស្វែងរកសន្តិភាពនៅ Mindanao៖ ភាពចាំបាច់ឲ្យមានរូបមន្តថ្មី" ឯកសារដែលបានធ្វើបទបង្ហាញនៅសន្និសីទ SEACSN៖ "បញ្ហា និងការប្រឈមនានាក្នុងការស្វែងរកសន្តិភាព និងដំណោះស្រាយជម្លោះនៅអាស៊ីអគ្នេយ៍" នៅសណ្ឋាគារ Shangri-La Hotel ក្រុង Penang ប្រទេសម៉ាឡេស៊ី ថ្ងៃទី១២-១៥ ខែមករា ឆ្នាំ២០០៤។

Lingga, Abhoud Syed M. ឆ្នាំ២០០៣ “តួនាទីរបស់ ស.រ.អា នៅក្នុងដំណើរការស្វែងរកសន្តិភាពនៅ Mindanao៖ ក្តីរំពឹងរបស់ Bangsa Moro” ការធ្វើបទបង្ហាញនៅក្នុងអង្គសន្និសីទស្តីអំពីតួនាទីរបស់ ស.រ.អា នៅក្នុងដំណើរការស្វែងរកសន្តិភាពនៅប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន, មជ្ឈមណ្ឌលអាស៊ី, សាកលវិទ្យាល័យហ្វីលីពីន, Diliman, ទីក្រុង Quezon, ប្រទេសហ្វីលីពីន ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៣។

Madale, Nagasura T. ឆ្នាំ១៩៩៩, ឆ្ពោះទៅការយល់ដឹងអំពីទស្សនៈ Bangsa/Bansa, នៅក្នុង បដិវត្តន៍នៅហ្វីលីពីន៖ ការបង្កើតប្រជាជាតិមួយ៖ ឯកសារពីសន្និសីទថ្នាក់តំបន់ ដែលប្រារព្ធនៅក្រុង Cebu, ក្រុង Davao, ក្រុង Baguio និងក្រុង Dapitan។ រដ្ឋធានីម៉ានីល៖ គណៈកម្មាធិការជាតិប្រារព្ធខួបមួយរយឆ្នាំ, វិទ្យាស្ថានសារព័ត៌មាន និងគមនាគមន៍។

Madale, Nagasura T. ឆ្នាំ២០០៣, “ជាបងប្អូននឹងគ្នា តែនៅតែជាមនុស្សមិនស្គាល់គ្នានៅលើ “ទឹកដីនៃការសន្យា”, Cagayan de Oro៖ សំណេរដែលមិនទាន់បោះពុម្ព។

កាសែត Manila Times ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៤ “ការមកដល់របស់ក្រុមការងារពីប្រទេសម៉ាឡេស៊ីជា “ដំណឹងល្អ” សម្រាប់ Mindanao គេហទំព័រ៖ http://www.manilatimes.net/national/2004/oct/10/yehey/top_stories/20041010 top8.html។

កាសែត Mindanao Times ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤, របៀបវារៈកំពូល៖ លោក Mahathir លោកស្រី Arroyo ជួបពិភាក្សាគ្នាអំពីកិច្ចខិតខំប្រឹងប្រែងស្វែងរកសន្តិភាព, គេហទំព័រ៖ http://www.mindanaotimes.com.ph/news/story.php?id=2257។

May, R. J. ឆ្នាំ២០០២, ជម្លោះនៃអំបូរម៉ូរ៉ូ និងបទពិសោធន៍នៅហ្វីលីពីនជាមួយស្វ័យភាពមូស្លីម, ឯកសារសម្រាប់សិក្ខាសាលា CCPCSAP ទីក្រុង Canberra ប្រទេសអូស្ត្រាលី។

Montalvan II, A. J. ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៤, “ការសិក្សាស្រាវជ្រាវ” អំពីសន្តិភាពនៅ Mindanao, INQ7.net, គេហទំព័រ៖ http://www.inq7.net/opi/2004/apr/05/opi_kris-1.htm។

Morgan, Shauna ឆ្នាំ២០០៣ “ឯករាជភាព ឬការពឹងពាក់គ្នាទៅវិញទៅមករបស់ Bangsamoro? សំណើសុំធ្វើប្រជាមតិ ដើម្បីឲ្យមានសន្តិភាពប្រកបដោយយុត្តិធម៌ និងយូរអង្វែងនៅ Mindanao” សំណេរដែលមិនទាន់បោះពុម្ពផ្សាយ សាកលវិទ្យាល័យ Toronto កាណាដា។

Muzaffar, C. ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៤, គំនិតដែលគួរឲ្យកោតសរសើរ យុត្តិធម៌៖ ចលនាអន្តរជាតិស្វែងរកយុត្តិធម៌នៅទូទាំងពិភពលោក, គេហទំព័រ៖ http://www.just-international.org/article.cfm?newsid=20000800។

Quevedo, Orlando B. ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤ “ភាពអយុត្តិធម៌៖ ឫសគល់នៃជម្លោះនៅ Mindanao” គេហទំព័រ៖ http://www.mindanews.com/peprcs/peacetalk/quevedo.shtml។

Rodil, Ruby B. ឆ្នាំ២០០៣ “ការស្ដាបនាសណ្ដាប់ធ្នាប់ជាថ្មីនៅក្នុងសហគមន៍ និងទំនាក់ទំនងរបស់វាទៅនឹងអភិរក្សជីវចម្រុះ” ឯកសារដែលធ្វើបទបង្ហាញនៅឯសិក្ខាសាលាស្ដីពី ការប្រែក្លាយជម្លោះ និងអភិរក្សជីវចម្រុះ, ក្រុង Cagayan de Oro ហ្វីលីពីន ថ្ងៃទី១១-១៣ ខែកក្កដា ឆ្នាំ២០០៣។

Rodil, Ruby B. ឆ្នាំ២០០០, Kalinaw Mindanaw៖ រឿងរ៉ាវស្ដីពីដំណើរការស្វែងរកសន្តិភាពរវាង GRP-MNLF ឆ្នាំ១៩៧៥-១៩៩៦។ Davao៖ វេទិកាមួយទៀតសម្រាប់ការស្រាវជ្រាវនៅ Mindanao។

Sharma, M. ឆ្នាំ២០០០, តួនាទីរបស់យុវជនក្នុងការលើកតម្កើងសន្តិភាព, គេហទំព័រ៖ http://www.friendspartners.org/GLOSAS/Global_University/Guideline/Sharma%27s_paper_on_Peace.html។

អង្គការសហប្រជាជាតិ គេហទំព័រ៖ http://www.un.org/english/។